


# បណ្ដាញធុរកិច្ចនៃចលនាបង្កើនអាហារូបត្ថម្ភកម្ពុជា

# យុទ្ធសាស្ត្រ ឆ្នាំ២០២១ - ២០២៥

គាំទ្រដោយៈ

ទីស្តីការគណៈរដ្ឋមន្ត្រី
ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (ក.ក.ជ.)

WFP
World Food Programme

# កំណត់សម្គាល់

ឯកសារនេះនឹងត្រូវធ្វើបច្ចុប្បន្នភាព នៅពេលដែលមានការប្រែប្រួលខ្លឹមសារនៅក្នុងឯកសារនេះ និងមានការផ្លាស់ប្តូរក្រុមការងារ SBN

ការត្រួតពិនិត្យកំណែ – សង្ខេបការធ្វើកំណែដោយសមាជិកក្រុម ក្នុងឯកសារយុទ្ធសាស្ត្រនេះ

| កំណែ | កាលបរិច្ឆេទ | សង្ខេបពីការផ្លាស់ប្តូរដែលបានធ្វើឡើង | ការផ្លាស់ប្តូររៀបចំដោយ |
|---|---|---|---|
| ១.១ | ខែមិថុនា ឆ្នាំ ២០២១ | កំណែបឋម | |
| | | | |
| | | | |

ការផ្លាស់ប្តូរនៅក្នុងឯកសារនេះ:

- ធ្វើការពិនិត្យយុទ្ធសាស្ត្រនេះឡើងវិញក្នុងមួយឆ្នាំម្តង ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ និងសមាជិករបស់ SBN កម្ពុជា
- ការផ្លាស់ប្តូរទាំងឡាយ ដែលអាចនាំមកនូវផលជះគួរឱ្យកត់សម្គាល់ គួរធ្វើឡើងដោយមានការឯកភាពពីតួអង្គពាក់ព័ន្ធសំខាន់ៗ នៅកម្រិតប្រទេស និងពីក្រុមការងារ SBN នៅកម្រិតសកល
- ការផ្លាស់ប្តូរសូចនាករប្រតិបត្តិការគន្លឹះ អាចធ្វើឡើងតែក្រោយកិច្ចប្រជុំពិនិត្យឡើងវិញលើយុទ្ធសាស្ត្រតែប៉ុណ្ណោះ

## ព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនង – សមាជិករបស់ក្រុមការងារ SBN


**ឯកឧត្តម សុខ ស៊ីឡូ**
អគ្គលេខាធិការក.ក.ជ. និងអ្នកសម្របសម្រួលចលនាបង្កើនអាហារូបត្ថម្ភនៅកម្ពុជា
អ៊ីមែល៖ soksilo@gmail.com
ទូរស័ព្ទ៖ +៨៥៥-១២-៤៥១ ១១១

**ហាក់ សុខជា**
អ្នកសម្របសម្រួល SBN កម្ពុជា
អ៊ីមែល៖ sokchea.hak@wfp.org
ទូរស័ព្ទ៖ +៨៥៥-៩៩-៣៣៣ ៦៨៣

**Emily Heneghan Kasoma**
Global network Co-Coordinator
អ៊ីមែល៖ emily.heneghan@wfp.org
ទូរស័ព្ទ៖ +២៦០៩៦២២៩០៣២១

**SBN Global**
អ៊ីមែល៖ secretariat@sunbusinessnetwork.org
គេហទំព័រ៖ sunbusinessnetwork.org

**SBN កម្ពុជា**
E: Cambodia.sbn@wfp.org
F: facebook.com/SUNBizCambodia

# ការអនុម័ត និងការផ្ដល់ការយល់ព្រម

## ការអនុម័ត និងការផ្ដល់ការយល់ព្រមដល់យុទ្ធសាស្ត្រ SBN កម្ពុជា

យុទ្ធសាស្ត្រសម្រាប់បណ្ដាញធុរកិច្ចនៃចលនាបង្កើនអាហារូបត្ថម្ភកម្ពុជា (SBN កម្ពុជា) ២០២១ – ២០២៥ ត្រូវបានរៀបចំតាក់តែង អនុម័ត និងទទួលបានការយល់ព្រមពីក្រុមការងារ ដែលជាតួអង្គពាក់ព័ន្ធ និងសហស្ថាបនិកនៃ SBN កម្ពុជា រួមមានតំណាងកម្មវិធីស្បៀងអាហារពិភពលោក (WFP) និងក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (ក.ក.ជ. )។

តួអង្គពាក់ព័ន្ធសំខាន់ៗទាំងនេះគឺជាអ្នកទទួលខុសត្រូវផ្ដល់ការណែនាំកម្រិតយុទ្ធសាស្ត្រ និងជាតុចូលក្នុងយុទ្ធសាស្ត្ររបស់ SBN កម្ពុជា ដោយឡែកក្រុមការងារ SBN កម្ពុជា ទទួលលើការអនុវត្តសូចនាករប្រតិបត្តិការគន្លឹះ ដែលត្រូវបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រនេះស្របតាមគុណតម្លៃស្នូលរបស់ SBN កម្ពុជា។

ការធ្វើបច្ចុប្បន្នភាព និងការកែសម្រួលយុទ្ធសាស្ត្រនេះត្រូវធ្វើឡើងស្របតាមនិតិវិធីដែលបានបង្ហាញជូននៅក្នុងកំណត់សម្គាល់ខាងដើម។  យុទ្ធសាស្ត្រសម្រាប់ SBN កម្ពុជា ២០២១ – ២០២៥ ត្រូវបានអនុម័ត និងផ្ដល់ការឯកភាពដោយ

ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (ក.ក.ជ.)

**ឯកឧត្តម សុខ ស៊ីឡូ**

អគ្គលេខាធិការ និងអ្នកសម្របសម្រួលចលនាបង្កើនអាហារូបត្ថម្ភនៅកម្ពុជា

កាលបរិច្ឆេទ៖ 27/12/2021

កម្មវិធីស្បៀងអាហារពិភពលោក (WFP)

**Claire Conan**

តំណាង និងជានាយកប្រចាំប្រទេស កម្ពុជា

កាលបរិច្ឆេទ៖ 27/12/21

# មាតិកា


១ សាវតារ និងទិដ្ឋភាពរួមទូទៅ 1



២ សង្ខេបយុទ្ធសាស្ត្រ 9



៣ សេចក្តីពន្យល់អំពីយុទ្ធសាស្ត្រ 13



៤ អភិបាលកិច្ច 35




៥ សមាជិករបស់ខ្លួន 39







# ១ សាវតារ និងទិដ្ឋភាពទូទៅ

បណ្ដាញធុរកិច្ចនៃចលនាបង្កើនអាហារូបត្ថម្ភ ក្នុងបរិបទទូទៅនៅកម្ពុជា

## ទិដ្ឋភាពរួមទូទៅចលនាបង្កើនអាហារូបត្ថម្ភ (SUN)

- ចលនាបង្កើនអាហារូបត្ថម្ភ(SUN) គឺជាចលនាសកលដែលមានគោលបំណងលុបបំបាត់នូវបញ្ហាអាហារូបត្ថម្ភគ្រប់ទម្រង់។
- បណ្ដាញធុរកិច្ចនៃចលនាបង្កើនអាហារូបត្ថម្ភ(SBN) គឺជាបណ្ដាញមួយក្នុងចំណោមបណ្ដាញតួអង្គពាក់ព័ន្ធនៅកម្រិតសកលចំនួន៤ នៃចលនាបង្កើនអាហារូបត្ថម្ភ បណ្ដាញធុរកិច្ច បណ្ដាញសង្គមស៊ីវិល បណ្ដាញអ្នកផ្ដល់ជំនួយ និងបណ្ដាញសហប្រជាជាតិដើម្បីអាហារូបត្ថម្ភ ។
- SBN មានគោលបំណងកៀរគរការចូលរួមរបស់វិស័យឯកជន ដើម្បីទាញប្រយោជន៍ពីជំនាញឯកទេស ការគ្របដណ្ដប់ទីផ្សារ និងឥទ្ធិពលលើទីផ្សាររបស់ពួកគេ ដើម្បីលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ។
- នៅកម្រិតសកល SBN ត្រូវបានបង្កើតនិងគាំទ្រសម្របសម្រួលដោយអង្គការ GAIN និង WFP និងបានទទួលការគាំទ្របន្ថែមទៀតពីក្រុមប្រឹក្សាផ្ដល់យោបល់នៃ Global SBN (SBN Advisory Group) ដែលរួមមាន ថ្នាក់ដឹកនាំជាន់ខ្ពស់មកពីវិស័យរដ្ឋ និងឯកជន។
- នៅកម្ពុជា SBN ត្រូវបានបង្កើតរួមគ្នាដោយក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (ក.ក.ជ.) & WFP និងសម្របសម្រួលដោយ WFP។

បណ្ដាញ ៣ ផ្សេងទៀតនៃចលនាបង្កើនអាហារូបត្ថម្ភនៅកម្ពុជា

**បណ្ដាញសហប្រជាជាតិដើម្បីអាហារូបត្ថម្ភ**

ទីភ្នាក់ងារសហប្រជាជាតិដែលធ្វើការងាររួមគ្នា ដើម្បីសម្របសម្រួលការចូលរួមរបស់អង្គការសហប្រជាជាតិ ក្នុងចលនាបង្កើនអាហារូបត្ថម្ភ

– WFP ជាប្រធាន

**បណ្ដាញអង្គការសង្គមស៊ីវិល**

អង្គការសង្គមស៊ីវិលដែលធ្វើការរួមគ្នា ដើម្បីបន្សីកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនឱ្យស្របតាមផែនការប្រចាំប្រទេស ដើម្បីបង្កើនអាហារូបត្ថម្ភ

– Helen Keller International ជាប្រធាន

**បណ្ដាញអ្នកផ្ដល់ជំនួយ**

អ្នកផ្ដល់ជំនួយដែលធ្វើការរួមគ្នា ដើម្បីបន្សី កៀរគរ និងតាមដាននូវធនធានដែលចាំបាច់សម្រាប់ផ្ដល់ការគាំទ្រដល់ចលនាបង្កើនអាហារូបត្ថម្ភ

– ស្ថានទូតអាល្លឺម៉ង់ ជាប្រធាន

តួអង្គនៅក្នុង SBN

សម្របសម្រួលនៅកម្រិតសកលដោយ៖ WFP និង GAIN
សម្របសម្រួលនៅកម្ពុជាដោយ៖ WFP
អ្នកសម្របសម្រួលចលនាបង្កើនអាហារូបត្ថម្ភនៅកម្ពុជា៖ អគ្គលេខាធិការក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

# សារៈសំខាន់នៃការជំរុញការចូលរួមរបស់វិស័យឯកជនក្នុងចលនាបង្កើនអាហារូបត្ថម្ភ

មានមូលហេតុធំៗចំនួន ៤ សម្រាប់ជំរុញការចូលរួមរបស់វិស័យឯកជន នៅក្នុងចលនាបង្កើនអាហារូបត្ថម្ភ

### គ្រប់វិស័យទាំងអស់សុទ្ធតែមានតួនាទីចូលរួម

- ចលនាបង្កើនអាហារូបត្ថម្ភនឹងសម្រេចបានផលជះធំធេងបំផុតតាមរយៈការប្រមូលផ្តុំធនធាន និងសមត្ថភាពពីចម្រុះវិស័យ និងការធានាបាននូវការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងទាំងនេះប្រកបដោយប្រសិទ្ធភាព
- វិស័យឯកជនអាចបំពេញបន្ថែមទៅ លើរបៀបវារៈអាហារូបត្ថម្ភរបស់រាជរដ្ឋាភិបាល តាមរយៈការគាំទ្រទៅលើចំណុចនានាដែលតួអង្គពាក់ព័ន្ធដទៃទៀតអាចពុំមានវិសាលភាពគ្របដណ្តប់ដល់ ឬពុំអាចមានផលជះគ្របដណ្តប់លើក្រុមអ្នកប្រើប្រាស់ក្នុងទ្រង់ទ្រាយធំបាន។

### វិស័យឯកជនមានតួនាទីសំខាន់សម្រាប់លើកកម្ពស់អាហារូបត្ថម្ភ

- ទីផ្សារសេរី គឺជាកន្លែងដែលមនុស្សភាគច្រើនទទួលបាននូវផលិតផល និងសេវាកម្ម ដើម្បីបំពេញតម្រូវការអាហារ និងតម្រូវការរបបអាហាររបស់ពួកគេ ដែលក្នុងនោះក៏រួមបញ្ចូលអតិថិជនជាអ្នកប្រើប្រាស់ចំនួន ៤,៥ ពាន់លាននាក់ដែលស្ថិតនៅបាតនៃពីរ៉ាមីត
- វិស័យឯកជនគឺជាប្រភពនវានុវត្តន៍ជាច្រើនដូចជា ផលិតផលនិងបច្ចេកវិទ្យាថ្មីៗ យន្តការផ្តល់ហិរញ្ញប្បទាន និងគំរូសម្រាប់ចែកចាយផលិតផលដែលចាំបាច់សម្រាប់បង្កើនអាហារូបត្ថម្ភប្រកបដោយចីរភាព។

### អាហារូបត្ថម្ភមានសារៈសំខាន់សម្រាប់វិស័យឯកជន

- អាហារូបត្ថម្ភផ្តល់នូវឱកាសសម្រាប់អភិវឌ្ឍន៍ទីផ្សារថ្មីៗ ដើម្បីបង្កើនបរិមាណលក់ និងប្រាក់ចំណេញ
- ការផ្តល់នូវអាហារូបត្ថម្ភល្អដល់បុគ្គលិក កម្មករនៅកន្លែងធ្វើការ នាំឱ្យមានការថយចុះនៅចំនួនថ្ងៃឈប់សម្រាកឈឺ និងគ្រោះថ្នាក់ ក៏ដូចជាបង្កើនផលិតភាពការងារ
- ការខាតបង់ផ្នែកសេដ្ឋកិច្ចដែលបង្កឡើងដោយសារបញ្ហាកង្វះអាហារូបត្ថម្ភរបស់កុមារមានទំហំធំគួរឱ្យកត់សម្គាល់។ ជារៀងរាល់ឆ្នាំនៅអាហ្វ្រិក និងអាស៊ីមានការខាតបង់ប្រមាណជា១១% នៃផលិតផលសរុបក្នុងស្រុក (ផ.ស.ស.) ដោយសារតែបញ្ហាអាហារូបត្ថម្ភ
- ការទទួលខុសត្រូវចំពោះសង្គមអាចបង្កើនកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុនឱ្យកាន់តែប្រសើរ។

### ចំណុចមានប្រៀបរបស់វិស័យឯកជន

វិស័យឯកជនអាចផ្តល់នូវសមត្ថភាពលើកកម្ពស់អាហារូបត្ថម្ភផ្សេងខុសពីវិស័យសាធារណៈដូចជា

- បង្កើតតម្រូវការផលិតផលអាហារដែលសម្បូរជីវជាតិ និងសេវាពាក់ព័ន្ធនានា
- ផ្តោតលើការពង្រីកទំហំផលិតកម្មប្រសិទ្ធភាព និងកាត់បន្ថយថ្លៃដើម
- ផ្តោតការយកចិត្តទុកដាក់លើនវានុវត្តន៍ និងការអភិវឌ្ឍផលិតផលថ្មី ដែលអាចធ្វើឱ្យផលិតផលសម្បូរជីវជាតិ កាន់តែមានតម្លៃសមរម្យ និងគួរឱ្យចង់បរិភោគ
- មានសមត្ថភាពក្នុងការអនុវត្តប្រព័ន្ធគ្រប់គ្រងគុណភាព និងប្រព័ន្ធសុវត្ថិភាពអាហារទៅក្នុងខ្សែច្រវាក់អាហារ។

# ហេតុអ្វីបានជាវិស័យឯកជននៅកម្ពុជាត្រូវការ SBN

ការស្រាវជ្រាវ ការសិក្សា ព្រមទាំងសិក្ខាសាលាជាមួយតួអង្គពាក់ព័ន្ធចម្រុះ និងការសម្ភាសទ្វេភាគីរបស់យើង កន្លងមកបានរកឃើញនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោមដែលវិស័យឯកជននៅក្នុងប្រទេសកម្ពុជាកំពុងជួបប្រទះពាក់ព័ន្ធនឹងស្ថានភាពអាហារូបត្ថម្ភនៅក្នុងប្រទេស

### បញ្ហាប្រឈមសំខាន់ៗពាក់ព័ន្ធនឹងការយល់ដឹងអំពីអាហារូបត្ថម្ភដែលល្អ និងតម្រូវការទីផ្សារ

- ការយល់ដឹង និងចំណេះដឹងអំពីបញ្ហាអាហារូបត្ថម្ភរបស់ជាតិ និងសារៈសំខាន់នៃអាហារូបត្ថម្ភដែលល្អនៅមានកម្រិតនៅឡើយក្នុង ចំណោមវិស័យឯកជន
- តម្រូវការអាហារដែលមានសុវត្ថិភាព និងសម្បូរជីវជាតិនៅមានកម្រិតទាប ព្រោះអ្នកប្រើប្រាស់ពុំបានទទួលការអប់រំអំពីសារៈសំខាន់នៃរបបអាហារសុខភាព
- ខ្វះផលិតផលអាហារផលិតក្នុងស្រុកដែលសម្បូរជីវជាតិ និងមានតម្លៃសមរម្យ
- ផលិតផលអាហារដែលសម្បូរជីវជាតិ និងទ្រទ្រង់សុខភាព ពុំសូវសម្បូរនៅតាមកន្លែងលក់រាយ ជាពិសេសនៅតំបន់ជនបទ
- ជំងឺកូវីដ១៩ បង្កផលប៉ះពាល់យ៉ាងធំធេងមកលើសន្តិសុខស្បៀង និងអាហារូបត្ថម្ភ បង្កការរំខានដល់ខ្សែច្រវាក់ផ្គត់ផ្គង់អាហារ និងធ្វើឱ្យមនុស្សជាច្រើននាក់ពុំមានអាហារហូបចុកគ្រប់គ្រាន់ដោយសារតែមានប្រាក់ចំណូលទាប ហើយអាហារមួយចំនួនមានតម្លៃខ្ពស់។

### បញ្ហាប្រឈមសំខាន់ៗពាក់ព័ន្ធនឹងការបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារ

- តម្រូវការអាហារបញ្ចូលមីក្រូសារជាតិនៅមានកម្រិតទាប
- កន្លងមក កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដើម្បីបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារ ត្រូវបានធ្វើឡើងតាមបែបដាច់ដោយឡែកពីគ្នា
- បញ្ហាប្រឈមធំៗដែលក្រុមហ៊ុនជួបប្រទះក្នុងការផលិតអាហារបញ្ចូលមីក្រូសារជាតិ រួមមាន ថ្លៃដើមខ្ពស់ និងការលំបាកនាំចូលគ្រឿងផ្សំ និងបរិក្ខា ក៏ដូចជាសមត្ថភាពនៅមានកម្រិត
- ផលិតករអាហារបញ្ចូលមីក្រូសារជាតិមួយចំនួនជួបប្រទះបញ្ហាបច្ចេកទេសក្នុងដំណើរការផលិត
- ការសហការរវាងស្ថាប័នស្រាវជ្រាវ និងវិស័យឯកជនដើម្បីបង្កើនជីវជាតិនៅក្នុងចំណីអាហារនៅមានកម្រិតនៅឡើយ
- បញ្ហាប្រឈមដទៃទៀតរួមមាន ការធានាគុណភាព និងការត្រួតពិនិត្យគុណភាព ការបង្កើតតម្រូវការ ការពិនិត្យតាមដាន និងការពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្តិ។

# ហេតុអ្វីបានជារាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ត្រូវការ SBN

យើងបានកំណត់រកឃើញចំណុចជួបគ្នាដូចខាងក្រោម* រវាង SBN និងកម្មវិធី/គម្រោងនានាដែលកំពុងអនុវត្តដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នៅកម្ពុជា

### ឱកាសសំខាន់ៗគាំទ្រដល់ គំនិតផ្ដួចផ្ដើមអាហារូបត្ថម្ភរបស់រាជរដ្ឋាភិបាលកម្ពុជា

- គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ ក.ក.ជ. ក្នុងការរៀបចំអភិក្រមផ្អែកតាមទីផ្សារសម្រាប់ប្រើប្រាស់ សំដៅពង្រីកគំនិតផ្ដួចផ្ដើមបញ្ចូលមីក្រូសារជាតិទៅក្នុងអង្ករ និងក្នុងចំណីអាហារនៅកម្ពុជា
- គាំទ្រដល់ការបង្កើត និងការប្រើប្រាស់ស្លាកសញ្ញាដែលជួយផ្សព្វផ្សាយផលិតផលអាហារដែលសម្បូរជីវជាតិ និងបញ្ចូលមីក្រូសារជាតិ
- គាំទ្រដល់គំនិតផ្ដួចផ្ដើមទឹកស្អាត និងអនាម័យរបស់រាជរដ្ឋាភិបាលក្រោមការដឹកនាំរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងអភិវឌ្ឍន៍ជនបទ
- គាំទ្រដល់គំនិតផ្ដួចផ្ដើម ភូមិ១ ផលិតផល១ (OVOP) ដែលអនុវត្តដោយក្រសួងពាណិជ្ជកម្ម និងគណៈកម្មការជាតិជំរុញចលនាភូមិមួយផលលិតផលមួយនៃ ក.ក.ជ.
- ផ្ដល់ការគាំទ្រដល់ការលើកកម្ពស់ស្ដង់ដារសុវត្ថិភាពអាហារនៅកម្ពុជា។

### ឱកាសសំខាន់ៗក្នុងការផ្ដុំកម្លាំងគ្នារវាង SBN កម្ពុជា និងកម្មវិធី/គម្រោងដែលកំពុងអនុវត្តដោយដៃគូអភិវឌ្ឍន៍នានា

- គម្រោងរោងចក្រកាត់ដេរនៅកម្ពុជា ដែលធ្វើការជាមួយនឹងរោងចក្រកាត់ដេរ ជាង ៥00 ចាប់អារម្មណ៍ចំពោះកម្មវិធីលើកកម្ពស់អាហារូបត្ថម្ភដល់កម្មករ និយោជិត
- អង្គការយូនីដូ មានគម្រោងជាច្រើន ដែលគាំទ្រដល់សហគ្រាសខ្នាតតូច មធ្យម និងឧស្សាហកម្ម
- កម្មវិធី CAPFish CAPTURE របស់អង្គការយូនីដូ បង្កើនគុណភាព និងសុវត្ថិភាពនៃខ្សែច្រវាក់តម្លៃជលផល
- អង្គការ OXFAM មានកម្មវិធីធុរកិច្ចប្រកបដោយការទទួលខុសត្រូវ
- កម្មវិធីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភពហុវិស័យ (MUSEFO) របស់ GIZ លទ្ធភាពកសាងភាពជាដៃគូជាមួយនឹងវិស័យឯកជនដើម្បីផលិតអាហារដែលមានសុវត្ថិភាព និងមានអាហារូបត្ថម្ភ
- ឱកាសសហការជាមួយសាកលវិទ្យាល័យ និងមជ្ឈមណ្ឌលស្រាវជ្រាវពាក់ព័ន្ធនឹងការអភិវឌ្ឍផលិតផលថ្មី និងសេវាលើកកម្ពស់អាហារូបត្ថម្ភ
- សម្របសម្រួលជាមួយនឹងសម្ព័ន្ធសង្គមស៊ីវិលនៃចលនាបង្កើនអាហារូបត្ថម្ភ និងសមាជិកនៃបណ្ដាញអ្នកផ្ដល់ជំនួយនៃចលនាបង្កើនអាហារូបត្ថម្ភ ដើម្បីកំណត់/រៀបចំផែនទីបង្ហាញពីគំនិតផ្ដួចផ្ដើមនានា ដែលមានការចូលរួមពីវិស័យឯកជន។

** សម្គាល់៖ បញ្ជីនេះមិនបានរៀបរាប់អស់ឱកាសនោះឡើយ*

# ការបង្ហាញពីយុទ្ធសាស្ត្រ SBN កម្ពុជា

## ទិដ្ឋភាពរួមទូទៅនៃយុទ្ធសាស្ត្រនេះ

- យុទ្ធសាស្ត្រនេះដាក់ចេញនូវចក្ខុវិស័យ និងគោលដៅសំខាន់ៗរបស់ SBN កម្ពុជា សម្រាប់រយៈពេល ៥ ឆ្នាំ ពីឆ្នាំ ២០២១ ដល់ឆ្នាំ ២០២៥ ស្របតាមយុទ្ធសាស្ត្រជាតិស្ដីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទី ២ យុទ្ធសាស្ត្រចលនាបង្កើនអាហារូបត្ថម្ភ ៣.0 និងយុទ្ធសាស្ត្រ SBN ៣.0
- ផ្នែកបន្ទាប់បង្ហាញពីសកម្មភាពដែលយើងគ្រោងទុក ដើម្បីឈានទៅសម្រេចចក្ខុវិស័យ និងគោលដៅទាំងនេះ
- តួនាទីរបស់យើង ក្នុងនាមជាក្រុមការងារ SBN កម្ពុជា គឺសម្របសម្រួលសកម្មភាពរបស់បណ្ដាញនេះ ដើម្បីផ្ដល់ការគាំទ្រដល់អ្នកទាំងអស់គ្នាដែលជាសមាជិករបស់បណ្ដាញ ក្នុងការអភិវឌ្ឍអាជីវកម្មរបស់អ្នក និងលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភរបស់អ្នកប្រើប្រាស់

## តើយុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងដោយរបៀបណា

- សិក្ខាសាលាស្ដីពី SBN ត្រូវបានរៀបចំឡើងកាលពីថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ ២០២១ ជាមួយអ្នកចូលរួមចំនួន ៤៨ នាក់ដែលជាតំណាងពីវិស័យឯកជន សមាគមធុរកិច្ច ស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារសហប្រជាជាតិ សង្គមស៊ីវិល សាកលវិទ្យាល័យ មជ្ឈមណ្ឌលស្រាវជ្រាវ ដើម្បីធ្វើបទឧទ្ទេសនាមពី SBN ប្រមូលធាតុចូល សម្រាប់បង្កើតបណ្ដាញនេះជាផ្លូវការ និងសម្រាប់រៀបចំយុទ្ធសាស្ត្រ SBN កម្ពុជា
- ការប្រជុំ ការសម្ភាសផ្ទាល់ជាមួយនឹងតួអង្គពាក់ព័ន្ធសំខាន់ៗ ដែលតំណាងឱ្យវិស័យឯកជន ដៃគូអភិវឌ្ឍន៍ សមាគមធុរកិច្ច និងស្ថាប័នសិក្សាស្រាវជ្រាវ
- កិច្ចសន្ទនាស្ដីពីប្រព័ន្ធស្បៀងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាច្រើនត្រូវបានរៀបចំឡើងក្រោមការសម្របសម្រួលរបស់ ក.ក.ជ. ចាប់ពីខែមករា រហូតដល់ខែមិថុនា ឆ្នាំ ២០២១

| | | | | |
|---|---|---|---|---|
| មតិត្រឡប់ដែលបានទទួលពីអ្នកចូលរួមក្នុងសិក្ខាសាលា SBN កាលពីខែកុម្ភៈ ឆ្នាំ ២០២១ | ការសម្ភាសជាមួយនឹងតួអង្គពាក់ព័ន្ធសំខាន់ៗ ដូចជា រាជរដ្ឋាភិបាល អ្នកផ្ដល់ជំនួយ សង្គមស៊ីវិល និងវិស័យឯកជន | ការស្រាវជ្រាវ និងការវិភាគអំពីការអនុវត្តល្អនៅក្នុងប្រទេស និងទីផ្សារផ្សេងទៀត | ធាតុចូល ទិសដៅ និងឯកសារដែលបានពីក្រុមការងារ SBN នៅថ្នាក់សកល និងថ្នាក់តំបន់ | សិក្ខាសាលាផ្ទៃក្នុង កិច្ចប្រជុំប្រមូលគំនិតនានា និងការសហការគ្នា |

- ក្រោយពេលដែលសេចក្ដីព្រាងទីមួយត្រូវបានរៀបចំរួច ក្រុមការងារ SBN បានរៀបចំកិច្ចប្រជុំបន្ថែមជាមួយនឹងតួអង្គពាក់ព័ន្ធសំខាន់ៗនៅក្នុងវិស័យអាហារូបត្ថម្ភ ដូចជា ក.ក.ជ. និងសមាជិក SBN កម្ពុជាមួយចំនួន
- បន្ទាប់មកយុទ្ធសាស្ត្រនេះ ត្រូវបានដាក់ជូន ក.ក.ជ. និងកម្មវិធីស្បៀងអាហារពិភពលោកដើម្បីសុំការឯកភាពចុងក្រោយ ហើយឯកសារនេះគឺជាកំណែចុងក្រោយដែលនឹងប្រើប្រាស់ជាមូលដ្ឋាននៅកម្រិតយុទ្ធសាស្ត្រ សម្រាប់បណ្ដាញនេះ ក្នុងរយៈពេល ៥ ឆ្នាំខាងមុខ



# គុណតម្លៃរបស់SBN កម្ពុជា

## មានគុណតម្លៃស្នូលចំនួន ៧ ដែលគាំទ្រដល់ SBN កម្ពុជា និងសកម្មភាពគ្រប់បែបយ៉ាងដែលយើងធ្វើ

### ទិដ្ឋភាពរួមទូទៅអំពីគុណតម្លៃស្នូល

- គុណតម្លៃស្នូលរបស់ SBN គឺជាត្រីវិស័យសម្រាប់សកម្មភាពរបស់យើង និងរៀបរាប់ពីឥរិយាបថរបស់យើងនៅក្នុងបរិយាកាសការងាររបស់យើង
- គុណតម្លៃទាំងនេះគាំទ្រដល់ចក្ខុវិស័យរបស់បណ្ដាញ កំណត់ពីវប្បធម៌របស់បណ្ដាញ និងឆ្លុះបញ្ចាំងពីអ្វីដែលបណ្ដាញមើលឃើញថាមានសារៈសំខាន់
- នៅពេលដែលបណ្ដាញនេះមានការរីកចម្រើន និងអភិវឌ្ឍន៍បន្ថែមទៀត គុណតម្លៃទាំងនេះ និងជួយកំណត់ពីអត្តសញ្ញាណរបស់យើង។ គោលបំណងសំខាន់គឺចង់ឱ្យគុណតម្លៃទាំងនេះចាប់ផ្ដើមជ្រាបចូលទៅក្នុងសកម្មភាពប្រចាំថ្ងៃ នៃបណ្ដាញនេះ និងនូវតែជាកម្លាំងចលករដ៏សំខាន់ នៅពេលដែលមានការផ្លាស់ប្ដូរក្រុមការងារ ចំនួនសមាជិកមានការកើនឡើង និងគំនិតផ្ដួចផ្ដើមនានាត្រូវបានបញ្ចូលបន្ថែម និងធ្វើបច្ចុប្បន្នភាព ឬត្រូវបានកែសម្រួលអាទិភាព

**ខិតខំដើម្បីរីកចម្រើន**

យើងផ្ដល់តម្លៃដល់លទ្ធផលចុងក្រោយ ព្រមទាំងលទ្ធផលនានា។ យើងផ្ដោតការយកចិត្តទុកដាក់លើសកម្មភាព។ យើងផ្ដោតលើការអនុវត្តជាក់ស្ដែង។ យើងមានគោលបំណងនាំមកនូវការរីកចម្រើន និងកែលម្អជានិច្ច។ យើងធ្វើការងារគ្រប់យ៉ាងប្រកបដោយគុណភាព។

**ដឹកនាំ**

យើងធ្វើការសម្រេចចិត្ត។ យើងទទួលខុសត្រូវលើសកម្មភាពរបស់យើង និងមានគណនេយ្យភាពចំពោះលទ្ធផលចុងក្រោយ។ យើងមិនរង់ចាំអ្នកដទៃដើម្បីចាប់ផ្ដើម យើងក៏មានការរំពឹងទុកដូចគ្នាចំពោះអ្នកពាក់ព័ន្ធរបស់យើងផងដែរ។ ពួកយើងគឺសកម្មមុន។

**ធ្វើឱ្យសាមញ្ញ**

យើងធ្វើការងារផ្ដោតចំគោលដៅ។ យើងកាត់បន្ថយសំណល់ឱ្យនៅជាអប្បរមា និងបង្កើតគុណតម្លៃឱ្យបានជាអតិបរមា។ យើងមិនធ្វើឱ្យការងារស្មុគស្មាញខ្លាំងពេកនោះឡើយ។ យើងប្រកាន់ភ្ជាប់ជានិច្ចចំពោះបុព្វហេតុរបស់យើង។

**គិតប្រកបដោយភាពច្នៃប្រឌិត**

យើងលើកទឹកចិត្ត និងគាំទ្រដល់នវានុវត្តន៍។ យើងមិនខ្លាចក្នុងការសាកល្បងនូវអ្វីដែលថ្មីដែលអាចផ្ដល់នូវគុណតម្លៃដល់សង្គមនោះឡើយ។

**ធ្វើការងាររួមគ្នា**

យើងចែករំលែក និងសហការគ្នាក្នុងគ្រប់ការងារទាំងអស់ដែលយើងធ្វើ។ យើងគឺជាក្រុមដែលធ្វើការងាររួមគ្នាដើម្បីលើកកម្ពស់អាហារូបត្ថម្ភសម្រាប់ប្រជាជនកម្ពុជា។

**ស្វែងយល់ និងអប់រំ**

យើងទទួលស្គាល់សារៈសំខាន់នៃក្រមសីលធម៌ និងសកម្មភាពដើម្បីសង្គមក្នុងទីផ្សារដែលមានភាពប្រកួតប្រជែង។ យើងមិនងាករេចេញពីគោលដៅចុងក្រោយរបស់យើង។ យើងធ្វើការតស៊ូមតិដើម្បីបុព្វហេតុរបស់យើង។

**បើកចំហ និងធ្វើការងារដោយសុទ្ធចិត្ត**

យើងធ្វើការប្រាស្រ័យទាក់ទងគ្នា។ យើងតែងតែព្យាយាមនិយាយត្រង់ទៅត្រង់មកជាមួយនឹងគ្នា និងជាមួយតួអង្គពាក់ព័ន្ធរបស់យើង។ យើងបង្ហាញពីភាពស្មោះត្រង់ ចំពោះគ្នាទៅវិញទៅមក។



១ សេចក្ដីសង្ខេបយុទ្ធសាស្ត្រ ២០២១ - ២០២៥

# យុទ្ធសាស្ត្រនៃ SBN កម្ពុជា ២០២១-២០២៥



## ចក្ខុវិស័យ

បំពេញតួនាទីជាវេទិកាសម្របសម្រួលដ៏សំខាន់មួយដែលផ្ដល់លទ្ធភាពឱ្យវិស័យឯកជនអាចចូលរួមចំណែកប្រកបដោយចីរភាពក្នុងការលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ



## គោលបំណង

ដើម្បីពង្រឹងការរួមចំណែករបស់វិស័យឯកជនដល់ការលើកកម្ពស់របបអាហារសុខភាព និងការលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប

## យើងនឹងសម្រេចចក្ខុវិស័យរបស់យើងតាមរយៈសសរស្តម្ភជាយុទ្ធសាស្ត្រចំនួន ៥

| ចំណុចផ្តោតរបស់យើង | ដឹកនាំ<br>ក្រុមការងារ SBN មានភាពម្ចាស់ការ និងដឹកនាំការងារដោយខ្លួនឯង | គាំទ្រ<br>ក្រុមការងារ SBN សម្របសម្រួលគំនិតផ្តួចផ្តើមទាំងនេះ និងបានទទួលការគាំទ្រនៅកម្រិតផ្សេងៗ ពីអ្នកផ្តល់ជំនួយ ដៃគូ និងសមាជិក | | | |
|---|---|---|---|---|---|
| សសរស្តម្ភជាយុទ្ធសាស្ត្រ | កសាងកេរ្តិ៍ឈ្មោះ SBN កម្ពុជាឱ្យបានរឹងមាំ និងកៀរគរសមាជិក | បង្កើនការយល់ដឹងពីអាហារូបត្ថម្ភ និងតម្រូវការអាហារសម្បូរជីវជាតិ | បង្កើនការផ្គត់ផ្គង់ផលិតផលអាហារដែលសម្បូរជីវជាតិ និងផលិតផលអាហារដែលបញ្ចូលមីក្រូសារជាតិ | ពង្រឹងបរិយាកាសអំណោយផលដើម្បីលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ | លើកកម្ពស់សុខភាព និងអាហារូបត្ថម្ភនៅតាមសហគមន៍ និងកន្លែងធ្វើការ |
| គំនិតផ្តួចផ្តើមជាអាទិភាព | • ជ្រើសរើស និងរក្សាទុកសមាជិកដែលមានកេរ្តិ៍ឈ្មោះ និងដែលមានការប្តេជ្ញាចិត្តខ្ពស់ រួមបញ្ចូលសហគ្រាសធុនតូច និងមធ្យម(SME) និងអាជីវកម្មដែលដឹកនាំដោយយុវជន និងស្ត្រីជាដើម<br>• ផ្តល់ឱកាសក្នុងការជួបជុំ និងចងក្រងបណ្តាញ<br>• បន្តរបៀបវារៈប្រាស្រ័យទាក់ទងគ្នាឱ្យបានសកម្ម<br>• កសាងក្របខ័ណ្ឌអភិបាលកិច្ចដែលសកម្ម និងប្រកបដោយគណនេយ្យភាព | • គាំទ្រដល់ស្លាកសញ្ញាដែលលើកកម្ពស់អាហារូបត្ថម្ភសមស្រប<br>• អនុវត្តយុទ្ធនាការបង្កើនការយល់ដឹង និងការផ្លាស់ប្តូរឥរិយាបថនៅក្នុងសង្គមតាមរយៈការប្រាស្រ័យទាក់ទង (SBCC) ដើម្បីលើកកម្ពស់ របបអាហារសុខភាព និងការអនុវត្តដែលលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ | • ផ្តល់ដំបូន្មាន ការណែនាំ ការបណ្តុះបណ្តាល និងផ្តល់ឧបករណ៍ ដើម្បីបង្កើនការចូលរួមរបស់វិស័យពាណិជ្ជកម្មនៅក្នុងអាហារូបត្ថម្ភ ដូចជា SME និង អាជីវកម្មដឹកនាំដោយស្ត្រីជាដើម<br>• ជម្រុញនវានុវត្តន៍ និងការអភិវឌ្ឍផលិតផលថ្មីៗ ដូចជាផលិតផលអាហារដែលសម្បូរជីវជាតិ និងផលិតផលអាហារដែលបញ្ចូលមីក្រូសារជាតិជាដើម<br>• បង្កើនភាពអាចរកបាននូវផលិតផលអាហារដែលសម្បូរជីវជាតិ និងអាហារដែលបញ្ចូល មីក្រូសារជាតិនៅតាមកន្លែងលក់រាយ<br>• បង្កើន និងសម្រួលឱ្យសមាជិកអាចទទួលបានជំនួយហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសជាមួយនឹងការផ្តោតពិសេសលើ SME និងអាជីវកម្មដឹកនាំដោយស្ត្រីជាដើម | • ជំរុញឱ្យមានការរៀបចំជាស្តង់ដារ លិខិតបទដ្ឋានគតិយុត្តិ ច្បាប់ គោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ<br>• ផ្តល់ធាតុចូល និងអនុសាសន៍ដល់រាជរដ្ឋាភិបាលនិងវិស័យឯកជនអំពីការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ<br>• ផ្តោតការយកចិត្តទុកដាក់លើគោលនយោបាយ និងការស្វែងរកការគាំទ្រ ដើម្បីដោះស្រាយបន្ទុកទ្វេ (double burden) នៃបញ្ហាអាហារូបត្ថម្ភ និងជំងឺមិនឆ្លង (NCDs) | • គាំទ្រដល់គំនិតផ្តួចផ្តើមសុខភាព និងអាហារូបត្ថម្ភនៅកន្លែងធ្វើការ<br>• ផ្តល់ការបណ្តុះបណ្តាល ការណែនាំ ឧបករណ៍ និងព័ត៌មាន និងចែករំលែកការអនុវត្តល្អ ព្រមទាំងចំណេះដឹងនានា<br>• បង្កើនការផ្គត់ផ្គង់ផលិតផល និងការរកដំណោះស្រាយដើម្បីលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភនៅតាមសហគមន៍<br>• លើកទឹកចិត្តឱ្យមានការគាំទ្រដល់អាហារូបត្ថម្ភតាមរយៈកម្មវិធីទំនួលខុសត្រូវសង្គមរបស់សាជីវកម្ម (CSR) |

| | | | | | |
|---|---|---|---|---|---|
| រង្វាស់ភាពជោគជ័យរបស់យើង (ត្រឹមចុងឆ្នាំ ២០២៥) (សូចនាករប្រតិបត្តិការគន្លឹះ ផ្ទាល់) | • សមាជិកយ៉ាងតិច ៥០ ត្រឹមចុងឆ្នាំ ២០២៣<br>• សមាជិកយ៉ាងតិច ១០០ ត្រឹមឆ្នាំ ២០២៥ រួមទាំងអាជីវកម្មដឹកនាំដោយស្ត្រីយ៉ាងតិច ២០<br>• ព្រឹត្តិបត្រសារព័ត៌មានប្រចាំត្រីមាស<br>• ព្រឹត្តិការណ៍ប្រចាំឆ្នាំយ៉ាងតិច ៦<br>• Facebook likes ជាង ១,000<br>• កិច្ចប្រជុំរបស់ក្រុមប្រឹក្សាផ្តល់យោបល់ត្រូវបានរៀបចំឡើងប្រចាំឆមាស | • ឯកសារទស្សនទានយ៉ាងតិច ១ ត្រូវបានរៀបចំឡើង និងចែករំលែកជារៀងរាល់ឆ្នាំ<br>• ដៃគូសក្តានុពលយ៉ាងតិច ៥ ត្រូវបានកំណត់ និងជួបប្រាស្រ័យទាក់ទងជារៀងរាល់ឆ្នាំ<br>• ផ្តល់ការគាំទ្រដល់ការអនុវត្តស្លាកសញ្ញាផលិតផលអាហារូបត្ថម្ភបានចំនួន ១<br>• យុទ្ធនាការបង្កើនការយល់ដឹងពីអាហារូបត្ថម្ភ/ SBCC ចំនួន ២ ទទួលថវិកាគាំទ្រ និងអនុវត្ត | • ចូលរួមចំណែកក្នុងគំនិតផ្តួចផ្តើមនវានុវត្តន៍/ ការអភិវឌ្ឍផលិតផលថ្មី/ ការបញ្ចូលមីក្រូសារជាតិ ការកែលម្អរូបមន្តផលិតយ៉ាងតិច ២ ក្នុងមួយឆ្នាំ<br>• សិក្ខាសាលាចែករំលែកការអនុវត្តល្អចំនួន ១ លើកក្នុង ១ ឆ្នាំ<br>• ព្រឹត្តិការណ៍ប្រចាំឆ្នាំយ៉ាងតិចចំនួន ៦<br>• យ៉ាងតិចមានអង្គភាពលក់រាយ ១ ត្រូវបានទាក់ទងឱ្យចូលរួមក្នុងសកម្មភាពអាហារូបត្ថម្ភជារៀងរាល់ឆ្នាំ<br>• សំណើគម្រោងយ៉ាងតិច ៥ ទទួលបានការគាំទ្រជាជំនួយបច្ចេកទេស/ថវិកា | • ឯកសារស្តីពីស្ថានភាពរបស់វិស័យឯកជន ក្នុងសកម្មភាពអាហារូបត្ថម្ភចំនួន ១ ត្រូវបានចេញផ្សាយជារៀងរាល់ឆ្នាំ<br>• ព្រឹត្តិការណ៍ តុមូល ចំនួន ២ លើកក្នុង ១ ឆ្នាំ ត្រូវបានរៀបចំឡើងជាមួយនឹងអ្នកតាក់តែងគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល<br>• ស្តង់ដារស្តីពីការបញ្ចូលមីក្រូសារជាតិទៅក្នុងអង្ករត្រូវបានត្រូវបានដាក់ចេញ | • យ៉ាងតិចក្រុមហ៊ុន ១0 អនុវត្តកម្មវិធី សុខភាព និងអាហារូបត្ថម្ភនៅកន្លែងធ្វើការ<br>• ឯកសារណែនាំ/ឧបករណ៍ស្តីពីការលើកកម្ពស់អាហារូបត្ថម្ភនៅកន្លែងធ្វើការយ៉ាងតិច ១ ត្រូវបានរៀបចំឡើង<br>• ការតភ្ជាប់ទំនាក់ទំនងយ៉ាងតិច ៥ ត្រូវបានធ្វើឡើងសម្រាប់ផលិតផល និងដំណោះស្រាយទាំងឡាយ ដើម្បីរួមចំណែកដល់ការលើកកម្ពស់អាហារូបត្ថម្ភ<br>• សមាជិក SBN យ៉ាងតិច ៥ បានចូលរួមនៅក្នុងគំនិតផ្តួចផ្តើមអាហារូបត្ថម្ភតាមរយៈកម្មវិធី CSR |
| តើជោគជ័យរបស់យើងមានលក្ខណៈយ៉ាងដូចម្តេចនៅត្រឹមចុងឆ្នាំ ២០២៥ (សូចនាករប្រតិបត្តិការគន្លឹះប្រយោល) | • សមាជិករបស់បណ្តាញរួមបញ្ចូល SME និងសហគ្រាសដឹកនាំដោយស្ត្រីមានការពេញចិត្ត ផ្តល់ការគាំទ្រ និងចូលរួមយ៉ាងសកម្ម<br>• សមាជិកក្លាយជាអ្នកដឹកនាំ និងមានភាពជាម្ចាស់លើគំនិតផ្តួចផ្តើមសំខាន់ៗតាមរយៈការចូលរួមនៅក្នុងសហគមន៍ការងារ (CoP)<br>• ផ្ទេរភាពជាម្ចាស់លើ SBN ជូនអ្នកពាក់ព័ន្ធនៅក្នុងប្រទេស | • ការយល់ដឹងរបស់អ្នកប្រើប្រាស់អំពីសារៈសំខាន់នៃរបបអាហារសុខភាព និងការអនុវត្តដែលលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភមានការកើនឡើង<br>• ផលិតផលអាហារដែលសម្បូរជីវជាតិមានច្រើននៅលើទីផ្សារ និងជាអាហារដែលអ្នកប្រើប្រាស់ចង់បាន<br>• តម្រូវការជាលក្ខណៈពាណិជ្ជកម្មនូវផលិតផលអាហារដែលសម្បូរជីវជាតិមានការកើនឡើង | • ការលក់ និងភាពចម្រុះនៃផលិតផលអាហារដែលសម្បូរជីវជាតិមានការកើនឡើង<br>• អ្នកប្រើប្រាស់ទទួលនូវការផ្សព្វផ្សាយពី និងអាចរកបាននូវផលិតផលអាហារដែលសម្បូរជីវជាតិ និងផលិតផលអាហារបញ្ចូលមីក្រូសារជាតិមានការកើនឡើង<br>• សហគ្រាសធុនតូច និងមធ្យម និងអាជីវកម្មដឹកនាំដោយស្ត្រីរួមចំណែកលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ | • វិធានលិខិតបទដ្ឋានគតិយុត្តិស្តីពីអាហារូបត្ថម្ភ ត្រូវបានកែលម្អ<br>• កិច្ចសន្ទនាជាប្រចាំ និងបើកចំហត្រូវបានធ្វើឡើងជាមួយនឹងរាជរដ្ឋាភិបាល<br>• ការបញ្ចូលមីក្រូសារជាតិត្រូវបានចាត់ទុកជាអាទិភាពឡើងវិញក្នុងរបៀបវារៈអាហារូបត្ថម្ភរបស់រាជរដ្ឋាភិបាល<br>• ការលើកកម្ពស់របបអាហារសុខភាពតាមរយៈបទដ្ឋានគតិយុត្តិតាមរបៀបវារៈច្បាស់លាស់ | • ការផ្សព្វផ្សាយ និងការផ្តល់លទ្ធភាពឱ្យកម្មករនិយោជិតអាចទទួលបានផលិតផលដែលសម្បូរជីវជាតិ ព្រមទាំងសេវាសុខភាព និងអាហារូបត្ថម្ភនៅកន្លែងធ្វើការរបស់ពួកគេកើនឡើង<br>• លើកកម្ពស់ស្ថានភាពទឹកស្អាត និងអនាម័យ នៅតាមសហគមន៍<br>• លទ្ធភាពទទួលបានអាហារដែលមានសុវត្ថិភាព សម្បូរជីវជាតិ និងមានតម្លៃសមរម្យកើនឡើង |






# កំណត់ពន្យល់អំពីយុទ្ធសាស្ត្រ

## ការបង្ហាញពិស្តារអំពីគោលដៅ និងគំនិតផ្តួចផ្តើមជាអាទិភាព

### ទិដ្ឋភាពរួមទូទៅ – តើផ្នែកនេះមានខ្លឹមសារអ្វីខ្លះ?

ផ្នែកនេះពន្យល់លម្អិតពីសសរស្តម្ភយុទ្ធសាស្ត្រទាំង ៥ ដែលត្រូវបានបង្ហាញនៅក្នុងផ្នែក 'យុទ្ធសាស្ត្រសង្ខេប' នៅក្នុងផ្នែកខាងលើ។ សម្រាប់គំនិតផ្តួចផ្តើមជាអាទិភាពនីមួយៗ ផ្នែកនេះរៀបរាប់ពី ថាតើគំនិតផ្តួចផ្តើម នេះ ជាគំនិតផ្តួចផ្តើម "អ្វី" និងថាតើSBNគ្រោងនឹងសម្រេចគំនិតផ្តួចផ្តើមទាំងនេះដោយ "របៀបណា"

### 'ផែនទីចំណុច' និង 'ការផ្តោតសំខាន់របស់យើងនៅទីនេះ' – តើជាអ្វី?

- 'ផែនទីចំណុច' បង្ហាញថាតើគំនិតផ្តួចផ្តើមណាមួយដែលកំពុងលើកយកមកពន្យល់បង្ហាញ ធៀបនឹងគំនិតផ្តួចផ្តើម ៥ ដទៃទៀត
- 'ការផ្តោតសំខាន់របស់យើងនៅទីនេះ' បង្ហាញពីកម្រិតនៃការចូលរួមរបស់ក្រុមការងារSBN ដើម្បីចូលរួមសម្រេចគំនិតផ្តួចផ្តើមនេះ

| | | | | | |
|---|---|---|---|---|---|
| របៀបអាន | ដឹកនាំ | គាំទ្រ | | | |
| | ១ | ២ | ៣ | ៤ | ៥ |
| ការផ្តោតសំខាន់របស់យើងនៅទីនេះ | ដឹកនាំ | "ក្រុមការងារ SBN មានភាពម្ចាស់ការដោយខ្លួនឯង និងដឹកនាំការងារដោយខ្លួនឯង" | | | |
| | គាំទ្រ | | | | |

### គន្លឹះ:

### ១. កម្រិតនៃផលជះ:

| | |
|---|---|
| H | ប្រសិនបើជោគជ័យ សក្តានុពលរបស់ផលជះវិជ្ជមាននៃគំនិតផ្តួចផ្តើមនេះ មាន**កម្រិតខ្ពស់** |
| M | ប្រសិនបើជោគជ័យសក្តានុពលរបស់ផលជះវិជ្ជមាននៃគំនិតផ្តួចផ្តើមនេះ មាន**កម្រិតមធ្យម** |
| L | ប្រសិនបើជោគជ័យ សក្តានុពលរបស់ផលជះវិជ្ជមាននៃគំនិតផ្តួចផ្តើមនេះ មាន**កម្រិតទាប** |

### ២. ក្រុមមុខសញ្ញានៃផលជះ:

| | |
|---|---|
| សមាជិក | ផលជះលើគុណតម្លៃ និងភាពឆ្លើយតបនៃSBN ចំពោះសមាជិករបស់ខ្លួន |
| អ្នកប្រើប្រាស់ | ផលជះលើភាពងាយស្រួលទទួលបានតម្លៃសមរម្យ និងភាពងាយរកបាន នៃផលិតផលអាហារូបត្ថម្ភសម្រាប់អ្នកប្រើប្រាស់ |
| ទីផ្សារ | ផលជះលើកំណើនទីផ្សារផលិតផលអាហារ និងភេសជ្ជៈ ដែលសម្បូរជីវជាតិ |
| អាហារូបត្ថម្ភ | ផលជះលើស្ថានភាពអាហារូបត្ថម្ភជារួមនៅកម្ពុជា |

# ទិដ្ឋភាពរួមនៃសសរស្តម្ភជាយុទ្ធសាស្ត្រ

សសរស្តម្ភជាយុទ្ធសាស្ត្រចំនួន ៥ ដូចដែលបានបង្ហាញនៅក្នុងផ្នែកយុទ្ធសាស្ត្រសង្ខេប បង្កើតបានជាមូលដ្ឋានសម្រាប់រៀបចំគំនិតផ្តួចផ្តើមជាអាទិភាពរបស់ SBN សម្រាប់រយៈពេល ៥ ឆ្នាំទៀត

## ទិដ្ឋភាពរួមនៃសសរស្តម្ភជាយុទ្ធសាស្ត្រ

- សសរស្តម្ភយុទ្ធសាស្ត្រទាំង ៥ នេះក៏ជាគោលដៅសំខាន់ៗរបស់SBN ផងដែរ ហើយសសរស្តម្ភទាំង ៥ នេះកំណត់ពីដំណើរឈានទៅសម្រេចចក្ខុវិស័យនៃបណ្តាញនេះ
- សសរស្តម្ភជាយុទ្ធសាស្ត្រទាំងនេះត្រូវបានរចនាតាក់តែងឡើងផ្អែកលើគោលការណ៍សំខាន់ៗចំនួន ២
  - **ភាពដាច់ដោយឡែកពីគ្នា** បើទោះជាសសរស្តម្ភទាំងនេះមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ក្នុងគោលបំណងសម្រេចចក្ខុវិស័យរបស់បណ្តាញក៏ដោយ សសរស្តម្ភនីមួយៗអាចផ្តាច់ចេញ និងអនុវត្តដាច់ដោយឡែកពីគ្នាបាន។ ការធ្វើបែបនេះផ្តល់លទ្ធភាពឱ្យSBN អាចមានភាពបត់បែនទៅតាមធនធាន និងការផ្លាស់ប្តូរសមត្ថភាពរបស់ក្រុមការងារ។
  - **កម្រិតនៃការផ្តោតការយកចិត្តទុកដាក់** ដោយសារតែ SBN គឺជាបណ្តាញដែលផ្តោតលើសមាជិក ផលជះដែលក្រុមការងារ SBN អាចមាននូវលទ្ធផលមួយចំនួននៅមានកម្រិត។ ដូច្នេះសសរស្តម្ភទាំងនេះត្រូវបានរចនាតាក់តែងឡើង ដើម្បីផ្តល់លទ្ធភាពឱ្យក្រុមការងារ SBN ផ្តោតការយកចិត្តទុកដាក់ខុសៗគ្នាលើសសរស្តម្ភនីមួយៗ។ កម្រិតនៃការផ្តោតការយកចិត្តទុកដាក់នេះ ត្រូវបានកំណត់ជា "**ដឹកនាំ**" ឬ "**គាំទ្រ**" ដូចពន្យល់ខាងក្រោម។

## ដឹកនាំ ឬ គាំទ្រ

- "ដឹកនាំ" ក្រុមការងារ SBN មានភាពម្ចាស់ការដោយខ្លួនឯង និងដឹកនាំការងារដោយខ្លួនឯង នេះមានន័យថាក្រុមការងារ SBN មានភារៈកិច្ចអនុវត្តគំនិតផ្តួចផ្តើមទាំងនេះ និងជាអ្នកទទួលខុសត្រូវផ្ទាល់លើលទ្ធផលចុងក្រោយនៃគំនិតផ្តួចផ្តើមនេះ
- "គាំទ្រ" ក្រុមការងារ SBN សម្របសម្រួលគំនិតផ្តួចផ្តើមទាំងនេះ និងបានទទួលការគាំទ្រនៅកម្រិតផ្សេងៗ ពីអ្នកផ្តល់ជំនួយ ដៃគូ និងសមាជិក  នេះមានន័យថាក្រុមការងារSBN បំពេញតួនាទីយ៉ាងសកម្មក្នុងការសម្របសម្រួលគំនិតផ្តួចផ្តើមទាំងនេះ ប៉ុន្តែក៏មានការពឹងផ្អែកក្នុងកម្រិតមួយលើតួអង្គដទៃទៀតផងដែរ ដើម្បីឈានទៅសម្រេចគំនិតផ្តួចផ្តើមទាំងនេះ

### សង្ខេបសសរស្តម្ភទាំង ៥

| សសរស្តម្ភជាយុទ្ធសាស្ត្រ | ១. កសាងកេរ្តិ៍ឈ្មោះ SBN កម្ពុជាឱ្យបានរឹងមាំ និងកៀរគរសមាជិក | ២. បង្កើនការយល់ដឹងពីអាហារូបត្ថម្ភ និងតម្រូវការអាហារសម្បូរជីវជាតិ | ៣. បង្កើនការផ្គត់ផ្គង់ផលិតផលអាហារដែលសម្បូរជីវជាតិ និងផលិតផលអាហារដែលបំប៉នមីក្រូសារជាតិ | ៤. ពង្រឹងបរិយាកាសអំណោយផល ដើម្បីលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ | ៥. លើកកម្ពស់សុខភាព និងអាហារូបត្ថម្ភនៅតាមសហគមន៍ និងកន្លែងធ្វើការ |
|---|---|---|---|---|---|
| តើវាជាអ្វី? | ជួយឱ្យ SBN កម្ពុជាក្លាយជាបណ្តាញដែលមានតម្លៃ ឆ្លើយតប និងឈានទៅបង្កើនចំនួនសមាជិក និងលើកកម្ពស់កេរ្តិ៍ឈ្មោះរបស់សមាជិក | បង្កើតតម្រូវការនៅក្នុងទីផ្សារឱ្យបានសកម្ម ដើម្បីបង្កឱកាសដល់អាជីវកម្មក្នុងការវិនិយោគនៅក្នុង វិស័យអាហារូបត្ថម្ភ | បំពាក់បំប៉នអាជីវកម្មនានា នូវចំណេះដឹង និងសមត្ថភាពបច្ចេកទេស ដើម្បីជួយឱ្យអាជីវកម្មទាំងនោះឈានជើងចូលទៅក្នុងទីផ្សារអាហារដែលសម្បូរជីវជាតិ និងអាហារបញ្ចូលមីក្រូសារជាតិ | ជួយកសាងបរិយាកាសច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តិកាន់តែប្រសើរ ដើម្បីលើកកម្ពស់ការបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារ និងការអភិវឌ្ឍផលិតផលដែលសម្បូរជីវជាតិ | លើកទឹកចិត្តឱ្យមានការលើកកម្ពស់សុខភាពកម្លាំងពលកម្មនៅតាមសហគ្រាសធំៗ និងជំរុញផ្សព្វផ្សាយពីផលិតផល និងដំណោះស្រាយ ដើម្បីលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភនៅក្នុងសហគមន៍ ក៏ដូចជាចែករំលែកឱកាស ដើម្បីឱ្យមានការចូលរួមក្នុងសកម្មភាព CSR បន្ថែមទៀត |

| | | | | | |
|---|---|---|---|---|---|
| របៀបអាន | ដឹកនាំ | គាំទ្រ | | | |
| | ១ | ២ | ៣ | ៤ | ៥ |

| | | |
|---|---|---|
| ការផ្ដោតសំខាន់របស់យើងនៅទីនេះ | ដឹកនាំ | "ក្រុមការងារ SBN មានភាពម្ចាស់ការដោយខ្លួនឯង និងដឹកនាំការងារដោយខ្លួនឯង" |
| | គាំទ្រ | |

# សសរស្តម្ភជាយុទ្ធសាស្ត្រទី ១ - គំនិតផ្ដួចផ្ដើម

## កសាងកេរ្តិ៍ឈ្មោះ SBN កម្ពុជាឱ្យបានរឹងមាំ និងកៀរគរសមាជិក

| គំនិតផ្ដួចផ្ដើម | សកម្មភាព | ដោយរបៀបណា | ផលជះ |
|---|---|---|---|
| ១.១ ជ្រើសរើស និងរក្សាឱ្យបាននូវសមាជិកដែលមានកេរ្តិ៍ឈ្មោះ និងមានការប្ដេជ្ញាចិត្តខ្ពស់ រួមបញ្ចូល SME និងអាជីវកម្មដឹកនាំដោយស្ត្រីនិងយុវជន | • បន្តជាប្រចាំធ្វើការចុះឈ្មោះសហគ្រាស និងស្ថាប័ននានាជាសមាជិករបស់ SBN កម្ពុជាជាផ្លូវការ<br>• ផ្ដោតគោលដៅលើអាជីវកម្មទាំងឡាយដែលមានឆន្ទៈក្នុងការចំណាយពេលវេលា និងធនធាន ដើម្បីអនុវត្តគំនិតផ្ដួចផ្ដើម SBN<br>• ធានាឱ្យសមាជិកភាពមានលក្ខណៈចម្រុះ ដូចជាក្រុមហ៊ុនពាក់ព័ន្ធផលិតផលអាហារ និងក្រុមហ៊ុនដែលមិនពាក់ព័ន្ធផលិតផលអាហារ ក្រុមហ៊ុនធំៗ សហគ្រាសធុនតូច និងមធ្យម កសិករ អ្នកនេសាទ និងអ្នកប្រមូលអនុផលព្រៃឈើខ្នាតតូច សមាគមអ្នកផលិត សហគមន៍ រួមបញ្ចូលសហគ្រាសនៅជនបទដែលមិនធ្វើសកម្មភាពកសិកម្ម និងក្រុមហ៊ុនបង្កើតថ្មីដោយផ្ដោតជាក់លាក់លើអាជីវកម្មដឹកនាំដោយស្ត្រីនិងយុវជន | • ផ្ដោតលើភាគីពាក់ព័ន្ធដែលធ្លាប់ធ្វើការជាមួយ ដើម្បីក្លាយជាសមាជិកស្ថាបនិកបណ្ដាញ<br>• បន្តជួបជាលក្ខណៈទ្វេភាគីជាមួយនឹងអាជីវកម្មគោលដៅមានដូចជា ក្រុមហ៊ុនជាតិ និងក្រុមហ៊ុនពហុជាតិសាសន៍ធំៗក្នុងវិស័យកសិអាហារ ក្រុមហ៊ុនលក់រាយ ភោជនីយដ្ឋាន ក្រុមហ៊ុនដែលមិនធ្វើការងារពាក់ព័ន្ធនឹងអាហារ អ្នកផ្ដល់សេវាដល់ SME សមាគមឧស្សាហកម្ម និងសភាពាណិជ្ជកម្ម។<br>• បន្តជួបជាមួយស្ថាប័នរាជរដ្ឋាភិបាល គ្រឹះស្ថានហិរញ្ញវត្ថុ ស្ថាប័នសិក្សាស្រាវជ្រាវ និងមជ្ឈមណ្ឌលស្រាវជ្រាវ ទីភ្នាក់ងារសហប្រជាជាតិ សម្ព័ន្ធសង្គមស៊ីវិល និងបណ្ដាញអ្នកផ្ដល់ជំនួយនៃចលនាបង្កើនអាហារូបត្ថម្ភ និងស្នើរអញ្ជើញអង្គភាពទាំងនេះឱ្យចូលរួមសហការជាមួយSBN និងអញ្ជើញឱ្យធ្វើជាសមាជិកនៃក្រុមប្រឹក្សាផ្ដល់យោបល់<br>• រៀបចំកម្មវិធីអប់រំផ្សព្វផ្សាយឱ្យបានសកម្ម ដើម្បីជ្រើសរើស SME ជាសមាជិក ដោយធ្វើការសហការជាមួយសហព័ន្ធ ឬសមាគមពាណិជកម្ម ដោយផ្ដោតជាបឋមលើ SME នៅក្នុងអនុវិស័យដែលផលិត និងផ្ដល់សេវាជំរុញលើកកម្ពស់អាទីភាពអាហារូបត្ថម្ភកម្ពុជា<br>• រៀបចំកម្មវិធីអប់រំផ្សព្វផ្សាយ ដើម្បីជ្រើសរើសអាជីវកម្មដឹកនាំដោយស្ត្រី ចូលជាសមាជិកSBN<br>• ស្នើសុំមតិត្រឡប់ និងធាតុចូលជាប្រចាំពីសមាជិកនានា និងធានាឱ្យមានការគិតគូរពិចារណាលើប្រយោជន៍ និងគំនិតផ្ដួចផ្ដើមរបស់សមាជិកដូចជាធ្វើការអង្កេត ដើម្បីកំណត់ពីតម្រូវការជំនួយបច្ចេកទេស និងតម្រូវការហិរញ្ញវត្ថុរបស់ SME | H សមាជិក<br>L អ្នកប្រើប្រាស់<br>M ទីផ្សារ<br>L ស្ថានភាពអាហារូបត្ថម្ភ |
| ១.២ ផ្ដល់ឱកាសក្នុងការជួបជុំនិងចងក្រងបណ្ដាញ | • ធានាថាសមាជិក SBN មានឱកាសជួប និងប្រាស្រ័យទាក់ទងជាមួយគ្នាដោយផ្ទាល់ ក៏ដូចជា ជាមួយអ្នកផ្ដល់ជំនួញ និងដៃគូដទៃទៀតជាទៀងទាត់<br>• រៀបចំព្រឹត្តិការណ៍ចែករំលែកចំណេះដឹង | • ផ្សារភ្ជាប់ទំនាក់ទំនងរវាងសមាជិក SBN ជាមួយនឹងទីភ្នាក់ងារសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍ដទៃទៀត ក៏ដូចជាជាមួយនឹងទីភ្នាក់ងាររាជរដ្ឋាភិបាល ដើម្បីទទួលបានជំនួយបច្ចេកទេស ដែលផ្ដល់ក្រោមកម្មវិធី / គម្រោងរបស់ស្ថាប័នទាំងនោះ<br>• រៀបចំព្រឹត្តិការណ៍រៀងរាល់ ២ខែម្ដងដូចជាវគ្គបណ្ដុះបណ្ដាល កម្មវិធីសន្ទនា វេទិកាធុរកិច្ច វេទិកាតុមូល<br>• អញ្ជើញមន្ត្រីរបស់រាជរដ្ឋាភិបាលឱ្យជួយលើកកម្ពស់ការយល់ដឹងដល់អាជីវកម្មនានា អំពីអាទិភាពអាហារូបត្ថម្ភ និងលិខិតបទដ្ឋានគតិយុត្តិ ដែលពាក់ព័ន្ធនឹងអាហារូបត្ថម្ភ<br>• ចែករំលែកព័ត៌មានល្អៗ និងមានប្រយោជន៍ដល់សមាជិកដូចជា ការស្រាវជ្រាវនៅក្នុងវិស័យឧស្សាហកម្ម ឯកសារណែនាំ ឧបករណ៍នានា<br>• ចែករំលែកព័ត៌មានដែលពាក់ព័ន្ធនឹងព្រឹត្តការណ៍ និងកិច្ចប្រជុំនានា ដែលរៀបចំដោយអង្គការស្ថាប័នដទៃទៀត ដែលអាចជាទីចាប់អារម្មណ៍របស់សមាជិក<br>• បង្កើតសហគមន៍អ្នកអនុវត្តការងារតាមវិស័យ (Community of Practices) ពាក់ព័ន្ធនឹងប្រធានបទសំខាន់ៗ ដែលជាទីចាប់អារម្មណ៍របស់សមាជិក SBN | H សមាជិក<br>M អ្នកប្រើប្រាស់<br>M ទីផ្សារ<br>L ស្ថានភាពអាហារូបត្ថម្ភ |

| គំនិតផ្តួចផ្តើម | សកម្មភាព | ដោយរបៀបណា | ផលជះ |
|---|---|---|---|
| ១.៣ បន្តរបៀបវារៈប្រាស្រ័យទាក់ទងគ្នាឱ្យបានសកម្ម | • ធានាថាសមាជិកSBN បានទទួលព័ត៌មានបច្ចុប្បន្នភាព អំពីSBN ក៏ដូចជាអំពីបណ្តាញដទៃទៀតនៃចលនាបង្កើនអាហារូបត្ថម្ភ គំនិតផ្តួចផ្តើម និងព្រឹត្តិការណ៍ផ្សេងៗ<br>• ធានាឱ្យមានការចែករំលែកព័ត៌មានអាហារូបត្ថម្ភសំខាន់ៗ រវាងវិស័យរដ្ឋ និងឯកជន ហើយសមាជិកបានដឹងពីកម្មវិធីអាហារូបត្ថម្ភជាតិ បញ្ហាប្រឈមនិងអាទិភាពនិន្នាការថ្មីៗនៅក្នុងទីផ្សារអាហារូបត្ថម្ភ ក៏ដូចជាលិខិតបទដ្ឋានគតិយុត្តិជាធរមាន និងដែលនឹងដាក់ចេញនាពេលខាងមុខ<br>• ស្វែងរកការគាំទ្រ ដើម្បីឱ្យវិស័យឯកជនអាចជួយគាំទ្រដល់ការសម្រេចបានអាទិភាពអាហារូបត្ថម្ភរបស់ជាតិ | • រៀបចំព្រឹត្តិបត្រសារព័ត៌មានប្រចាំត្រីមាសដោយបញ្ចូលប្រធានបទជាអាទិ៍<br>  • បច្ចុប្បន្នភាពស្តីពីគំនិតផ្តួចផ្តើម SBN ដែលរៀបចំដោយក្រុមការងារ SBN កម្ពុជា និង Global SBN<br>  • ព្រឹត្តិការណ៍ដែលនឹងរៀបចំនៅពេលខាងមុខ (ទាំងក្នុងក្របខ័ណ្ឌ SBN និងសហគមន៍អ្នកអនុវត្តការងារតាមវិស័យ)<br>  • ព័ត៌មានអំពីគំនិតផ្តួចផ្តើមពាក់ព័ន្ធនឹងអាហារូបត្ថម្ភរបស់សមាជិកនៃSBN<br>  • កម្រងព័ត៌មាននៃអាជីវកម្មដែលមានស្ត្រីជាអ្នកដឹកនាំ ឬជាម្ចាស់ ដែលបានរួមចំណែកដល់ការសម្រេចអាទិភាពអាហារូបត្ថម្ភ<br>  • ករណីសិក្សាអន្តរជាតិ<br>  • ព័ត៌មានពីទីផ្សារអាហារូបត្ថម្ភនៅកម្ពុជា<br>  • ព័ត៌មានបច្ចុប្បន្នភាពអំពីអាទិភាពអាហារូបត្ថម្ភ និងលិខិតបទដ្ឋានគតិយុត្តិរបស់រាជរដ្ឋាភិបាល<br>• បង្កើតទំព័រ Facebook មួយដែលមានឈ្មោះថា "SBN Cambodia" និងផ្សព្វផ្សាយព័ត៌មានបច្ចុប្បន្នភាពប្រចាំខែ<br>• ភ្ជាប់តំណរភ្ជាប់តាមរយៈគណនីអ៊ីម៉ែលរបស់ SBN<br>• ផ្សព្វផ្សាយទំព័រ Facebook ឱ្យបានសកម្មលើព្រឹត្តិបត្រសារព័ត៌មាន និងក្នុងគ្រប់ព្រឹត្តិការណ៍ទាំងអស់ | H សមាជិក<br>L អ្នកប្រើប្រាស់<br>M ទីផ្សារ<br>L ស្ថានភាពអាហារូបត្ថម្ភ |
| ១.៤ កសាងក្របខ័ណ្ឌអភិបាលកិច្ចដែលសកម្ម និងប្រកបដោយគណនេយ្យភាព | • បង្កើតក្រុមប្រឹក្សាផ្តល់យោបល់ SBN ដែលមានអាណត្តិយ៉ាងតិចណាស់ ២ឆ្នាំ ដើម្បីផ្តល់ការណែនាំនូវកម្រិតយុទ្ធសាស្ត្រ<br>• បង្កើតគណៈកម្មាធិការស្ថាបនិក ប្រកបដោយគណនេយ្យភាពដែលមានសមាជិកមកពី ក.ក.ជ. និង WFP ដើម្បីពិនិត្យលើវឌ្ឍនភាពនានា<br><br>*សម្គាល់៖ ព័ត៌មានលម្អិតបន្ថែមសូមមើលត្រង់ផ្នែករចនាសម្ព័ន្ធអភិបាលកិច្ច* | • រៀបចំតួនាទីនិងភារកិច្ច (TOR) សម្រាប់ក្រុមប្រឹក្សាផ្តល់យោបល់ និងសមាជិករបស់ក្រុមនេះ<br>• កំណត់ជ្រើសរើសសមាជិកក្រុមប្រឹក្សាផ្តល់យោបល់ សមាជិកគួរមកពីវិស័យឯកជន (ច្រើនជាង ៥0%) រាជរដ្ឋាភិបាល អ្នកផ្តល់ជំនួយ គ្រឹះស្ថានហិរញ្ញវត្ថុ អង្គការសង្គមស៊ីវិល ទីភ្នាក់ងារសហប្រជាជាតិ និងសមាជិកសំខាន់របស់សហគមន៍អ្នកអនុវត្តការងារតាមវិស័យ។ គួរមានតំណាង SME នៅក្នុងក្រុមប្រឹក្សាផ្តល់យោបល់នេះ<br>• ទាក់ទងទៅកាន់បុគ្គលគោលដៅ និងអញ្ជើញឱ្យធ្វើជាសមាជិកក្រុមប្រឹក្សាផ្តល់យោបល់។ សមាជិករបស់ក្រុមប្រឹក្សាផ្តល់យោបល់ ត្រូវតែជាសមាជិកនៃSBN<br>• ត្រៀម សម្របសម្រួល និងរៀបចំកិច្ចប្រជុំប្រចាំឆមាសរបស់ក្រុមប្រឹក្សាផ្តល់យោបល់ | M សមាជិក<br>L អ្នកប្រើប្រាស់<br>M ទីផ្សារ<br>L ស្ថានភាពអាហារូបត្ថម្ភ |

# សសរស្តម្ភជាយុទ្ធសាស្ត្រទី១-សូចនាករប្រតិបត្តិការគន្លឹះ

កសាងកេរ្តិ៍ឈ្មោះSBN ឱ្យបានរឹងមាំ និងកៀរគរសមាជិក

| របៀបអាន | ដឹកនាំ | គាំទ្រ | | | |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ៥ |

| ការផ្តោតសំខាន់របស់យើងនៅទីនេះ | ដឹកនាំ / គាំទ្រ | "ក្រុមការងារ SBN មានភាពម្ចាស់ការដោយខ្លួនឯង និងដឹកនាំការងារដោយខ្លួនឯង" |
|---|---|---|

## សូចនាករប្រតិបត្តិការគន្លឹះ ផ្ទាល់ – វង្វាស់ភាពជោគជ័យសម្រាប់

| សូចនាករប្រតិបត្តិការគន្លឹះ | សេចក្តីពិពណ៌នា | រយៈពេល |
|---|---|---|
| សមាជិកយ៉ាងតិច ៥០ ត្រឹមចុងឆ្នាំ ២០២៣ | • SBN មានសមាជិកយ៉ាងតិច៥០ បានចុះឈ្មោះជាផ្លូវការ<br>• សមាជិកទាំងអស់ត្រូវមានឈ្មោះនៅក្នុងបញ្ជីអ៊ីម៉ែលដែលនឹងត្រូវទទួលបានព្រឹត្តិបត្រព័ត៌មាន ព័ត៌មានបច្ចុប្បន្នភាពលិខិតអញ្ជើញ។ល។ | ត្រឹមចុងឆ្នាំ ២០២៣ (នឹងត្រូវពិនិត្យឡើងវិញនៅក្នុងឆ្នាំ ២០២៤) |
| សមាជិកយ៉ាងតិច ១០០ ត្រឹមឆ្នាំ ២០២៥ រួមទាំងអាជីវកម្មដឹកនាំដោយស្ត្រី យ៉ាងតិច ២០ | • ជ្រើសរើស SME យ៉ាងតិចចំនួន ១០០ ជាសមាជិក តាមរយៈSBN ដោយផ្ទាល់ ឬតាមរយៈ សម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា ឬសមាគមឧស្សាហកម្ម ស្ថាប័ន និងកម្មវិធីនានា ឬក្រុមផលិត និងសហគមន៍ដទៃទៀត ដែលក្នុងចំណោមនោះយ៉ាងតិចណាស់មាន SME ចំនួន ២០ មានស្ត្រីជាម្ចាស់ ឬ ជាអ្នកដឹកនាំ។ ការជ្រើសរើសជាសមាជិក រួមទាំងការផ្តល់កិច្ចគាំទ្រនឹងធ្វើឡើងជាអាទិភាពសម្រាប់ SME ដែលផលិតនូវផលិតផលឬផ្តល់សេវា ដែលជំរុញឱ្យសម្រេចបាននូវអាទិភាពអាហារូបត្ថម្ភរបស់កម្ពុជា។ | ត្រឹមចុងឆ្នាំ ២០២៥ |
| ព្រឹត្តិបត្រសារព័ត៌មានប្រចាំត្រីមាស | • រៀបចំ និងផ្ញើព្រឹត្តិបត្រសារព័ត៌មានរបស់SBN កម្ពុជា ដូចបញ្ជាក់ជូននៅក្នុងផ្នែក 'ដោយរបៀបណា' ក្រោមគំនិតផ្តួចផ្តើម ១.៣<br>• ផ្ញើព្រឹត្តិបត្រព័ត៌មាន ៤ លើកក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ ២០២៣ និង ២០២៥ | ត្រឹមចុងឆ្នាំ ២០២៥ |
| ព្រឹត្តិការណ៍ប្រចាំឆ្នាំ យ៉ាងតិច ៦ | • រៀបចំព្រឹត្តិកាណ៍យ៉ាងតិចណាស់ចំនួន ៦លើកក្នុងមួយឆ្នាំ ដូចបញ្ជាក់ជូននៅក្នុងផ្នែក 'ដោយរបៀបណា' ក្រោមគំនិតផ្តួចផ្តើម ១.២ | ត្រឹមចុងឆ្នាំ ២០២៥ |
| Facebook likes ជាង ១,000 | • បង្កើនវត្តមានតាមបណ្តាញទំនាក់ទំនងសង្គមនៅក្នុងឆ្នាំទីមួយ តាមរយៈការផ្សព្វផ្សាយឱ្យបានសកម្ម ដើម្បីទទួលបាន 'likes' យ៉ាងតិចណាស់ ១000 នៅលើទំព័រ Facebook របស់SBN កម្ពុជា<br>• ផ្តោតលើសមាជិក SBN កម្ពុជា សហគមន៍អ្នកផ្តល់ជំនួយ សង្គមស៊ីវិល ទីភ្នាក់ងារសហប្រជាជាតិ ស្ថាប័នរាជរដ្ឋាភិបាល សមាគមឧស្សាហកម្ម សភាពាណិជ្ជកម្ម និងសមាជិកដទៃទៀតនៅក្នុងសហគមន៍អ្នកអនុវត្តន៍តាមវិស័យ (ឧទាហរណ៍ មិត្តភក្តិ គ្រួសារ បណ្តាញវិជ្ជាជីវៈ។ល។) | ត្រឹមចុងឆ្នាំ ២០២២ (នឹងត្រូវពិនិត្យឡើងវិញនៅក្នុងឆ្នាំ ២០២៣) |
| កិច្ចប្រជុំរបស់ក្រុមប្រឹក្សាផ្តល់យោបល់ត្រូវបានរៀបចំឡើងប្រចាំឆមាស | • បង្កើតក្រុមប្រឹក្សាផ្តល់យោបល់ ដូចរៀបរាប់នៅក្នុងគំនិតផ្តួចផ្តើម១.៤ និងកៀរគរសមាជិកឱ្យបានចូលរួមពេញលេញ<br>• រៀបចំ និងសម្របសម្រួលកិច្ចប្រជុំរបស់ក្រុមប្រឹក្សាផ្តល់យោបល់ប្រចាំឆមាស | ត្រឹមចុងឆ្នាំ ២០២៥ (កិច្ចប្រជុំរបស់ក្រុមប្រឹក្សាផ្តល់យោបល់នឹងត្រូវរៀបចំឡើងប្រចាំត្រីមាស) |

## សូចនាករប្រតិបត្តិការគន្លឹះ ប្រយោល – លទ្ធផលចុងក្រោយដែលចង់សម្រេចឱ្យបាន ឬអត្ថប្រយោជន៍ដែលគំនិតផ្តួចផ្តើមជាអាទិភាពត្រូវបានរៀបចំឡើងដើម្បីសម្រេច

| សូចនាករប្រតិបត្តិការគន្លឹះ | សេចក្តីពិពណ៌នា | រយៈពេល |
|---|---|---|
| សមាជិករបស់បណ្តាញរួមបញ្ចូល SME និងសហគ្រាសដឹកនាំដោយស្ត្រី មានការពេញចិត្ត ផ្តល់ការគាំទ្រ និងចូលរួមយ៉ាងសកម្ម | • សមាជិកភាគច្រើនចាត់ទុកបណ្តាញនេះថាជាវេទិកាសម្របសម្រួល និងកសាងសមត្ថភាពដ៏សំខាន់ដែលស្ថិតនៅខាងក្រោយនៃការវិនិយោគរបស់វិស័យឯកជនក្នុងសកម្មភាពពាក់ព័ន្ធនឹងអាហារូបត្ថម្ភ<br>• សមាជិកភាគច្រើនចូលរួមយ៉ាងសកម្មនូវគំនិតផ្តួចផ្តើមរបស់ SBN កម្ពុជា និងចំណាយពេលវេលាក៏ដូចជាធនធានរបស់ខ្លួន ដើម្បីផ្សព្វផ្សាយពី SBN កម្ពុជា និងសកម្មភាពរបស់បណ្តាញ<br>• សមាជិកបំពេញតួនាទីជាអ្នកដឹកនាំ និងទទួលយកភាពជាម្ចាស់លើគំនិតផ្តួចផ្តើមសំខាន់ៗ តាមរយៈការចូលរួមនៅក្នុងសហគមន៍អ្នកអនុវត្តន៍តាមវិស័យ | ត្រឹមចុងឆ្នាំ ២០២៥ |
| ផ្ទេរភាពជាម្ចាស់លើ SBN ជូនអ្នកពាក់ព័ន្ធនៅក្នុងប្រទេស | • ប្តូរគណនេយ្យភាព និងភាពជាម្ចាស់ពី WFP / ក.ក.ជ.  ដែលជាស្ថាបនិកបណ្តាញ ទៅតួអង្គពាក់ព័ន្ធនៅក្នុងប្រទេស (នេះអាចជាសមាគមធុរកិច្ចនៅក្នុងប្រទេស ឬស្ថាប័នវិស័យឯកជនណាមួយ។ល។)<br>• ប្តូរតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាផ្តល់យោបល់ពីតួអង្គដែលផ្តល់ការណែនាំកម្រិតយុទ្ធសាស្ត្រ ទៅជាតួអង្គដែលមានគណនេយ្យភាពចំពោះសកម្មភាព SBN កម្ពុជា និងកាន់តែមានអំណាចនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត<br>• ក.ក.ជ. និង WFP ព្រមទាំងភាគីមិនមែនវិស័យឯកជនដែលពាក់ព័ន្ធដទៃទៀតអាចចូលរួមជាសមាជិកក្រុមប្រឹក្សាផ្តល់យោបល់ ប៉ុន្តែសមាជិកច្រើនជាង៥0% គួរមកពីវិស័យឯកជន<br><br>*កំណត់សម្គាល់៖ ព័ត៌មានលម្អិតក្រោមផ្នែក 'រចនាសម្ព័ន្ធអភិបាលកិច្ច'* | ត្រឹមចុងឆ្នាំ ២០២៥ |

# សសរស្តម្ភជាយុទ្ធសាស្ត្រទី ២ - គំនិតផ្តួចផ្តើម

## បង្កើនការយល់ដឹងពីអាហារូបត្ថម្ភ និងតម្រូវការអាហារសម្បូរជីវជាតិ

| របៀបអាន | ដឹកនាំ | គាំទ្រ | | | |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ៥ |

| ការផ្តោតសំខាន់របស់យើងនៅទីនេះ | |
|---|---|
| ដឹកនាំ | "ក្រុមការងារ SBN សម្របសម្រួលគំនិតផ្តួចផ្តើមទាំងនេះ និងបានទទួលការគាំទ្រនៅកម្រិតផ្សេងៗ ពីអ្នកផ្តល់ជំនួយ ដៃគូ និងសមាជិក" |
| គាំទ្រ | |

| គំនិតផ្តួចផ្តើម | សកម្មភាព | ដោយរបៀបណា | ផលជះ |
|---|---|---|---|
| ២.១<br>គាំទ្រដល់ស្លាកសញ្ញាដែលលើកកម្ពស់អាហារូបត្ថម្ភសមស្រប | • គាំទ្រដល់ការអនុវត្តស្លាកសញ្ញាអាហារដែលមានបញ្ចូលមីក្រូសារជាតិ ក៏ដូចជាស្លាកសញ្ញា ផលិតផលអាហារទ្រទ្រង់សុខភាព និងអាហារូបត្ថម្ភដទៃទៀត<br>• គោលបំណងគឺជំរុញឱ្យមានការបរិភោគអាហារសម្បូរជីវជាតិ និង កសាងការជឿទុកចិត្តរបស់អ្នកប្រើប្រាស់ និងការគោរពតាមច្បាប់នៅក្នុងឧស្សាហកម្មនេះ | • រិះរកឱកាសសហការជាមួយនឹងអង្គការយូនីដូ (UNIDO) ដើម្បីអនុវត្ត សញ្ញាគុណភាពកម្ពុជា (Cambodia Quality Seal)<br>• គាំទ្រដល់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីរៀបចំ និងផ្សព្វផ្សាយស្លាកសញ្ញាអាហារូបត្ថម្ភដែលបិទនៅផ្នែកខាងមុខនៃកញ្ចប់ផលិតផល<br>• រៀបចំឯកសារទស្សនទានស្តីពីការផ្សព្វផ្សាយយីហោអាហារបញ្ចូលមីក្រូសារជាតិ ដោយត្រូវបញ្ចូលគោលដៅអ្នកប្រើប្រាស់ជាមុខសញ្ញា ផលិតផលជាមុខសញ្ញា ដំណើរការអនុលោមតាមច្បាប់ ភាគីដែលផ្តល់ការគាំទ្រ និងលទ្ធផលដែលចង់បាន<br>• ធ្វើការស្រាវជ្រាវលើដំណើរការទីផ្សារ វិភាគ និងសម្ភាសអ្នកពាក់ព័ន្ធ<br>• រៀបចំយុទ្ធនាការបង្កើនការយល់ដឹងពីស្លាកសញ្ញាអាហារូបត្ថម្ភ ឱ្យបានពេញលេញដោយត្រូវបញ្ចូលការប៉ាន់ប្រមាណចំណាយលម្អិត និងពេលវេលាដែលត្រូវអនុវត្ត<br>• សម្របសម្រួល និងអនុវត្តយុទ្ធនាការបង្កើនការយល់ដឹងអំពីស្លាកសញ្ញាអាហារូបត្ថម្ភជាមួយនឹងរាជរដ្ឋាភិបាលដោយមានការគាំទ្រពាក់ព័ន្ធពីភាគីទី ៣ ដូចជាអ្នករចនាក្រាហ្វិច អ្នកជំនាញខាងអាហារូបត្ថម្ភ ស្ថាប័នផ្តល់វិញ្ញាបនប័ត្រ ប្រព័ន្ធគុណភាព។ល។ | H សមាជិក<br>H អ្នកប្រើប្រាស់<br>H ទីផ្សារ<br>M ស្ថានភាពអាហារូបត្ថម្ភ |
| ២.២<br>អនុវត្តយុទ្ធនាការបង្កើនការយល់ដឹង និង ការផ្លាស់ប្តូរឥរិយាបថនៅក្នុងសង្គមតាមរយៈការប្រាស្រ័យទាក់ទង (SBCC) ដើម្បីលើកកម្ពស់ របបអាហារសុខភាព និងការអនុវត្តដែលលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ | • បង្កើនការយល់ដឹងឱ្យបានទូលំទូលាយ និងយុទ្ធនាការផ្លាស់ប្តូរ ឥរិយាបថសង្គមតាមរយៈការប្រាស្រ័យទាក់ទង<br>• បង្កើនការយល់ដឹងពីអាហារូបត្ថម្ភ ដែលល្អ និងរបបអាហារទ្រទ្រង់សុខភាព និងបង្កើនការបរិភោគផលិតផល ដែលសម្បូរជីវជាតិ | • គាំទ្រដល់ ក.ក.ជ. ក្នុងការអនុវត្តយុទ្ធនាការ SBCC រួម ដើម្បីលើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ<br>• ស្វែងរកតារាល្បី/ អ្នកដែលមានឥទ្ធិពលតាមបណ្តាញទំនាក់ទំនងសង្គម ដើម្បីឱ្យពួកគេក្លាយជាតារាឆ្នើមសម្រាប់លើកកម្ពស់អាហារូបត្ថម្ភនៃSBN<br>• ស្វែងរកដៃគូវិស័យឯកជន (ឧទាហរណ៍ ក្រុមហ៊ុនផ្សព្វផ្សាយនៅក្នុងស្រុក ក្រុមហ៊ុនទូរគមនាគមន៍) ដើម្បីឧបត្ថម្ភដល់យុទ្ធនាការតាមបណ្តាញផ្សព្វផ្សាយ (អាចជាប្រព័ន្ធផ្សព្វផ្សាយ (ទូរទស្សន៍/កម្មវិធី ចម្អិនម្ហូប វីឡូ) ក្នុងបណ្តាញទំនាក់ទំនងសង្គម តាមប្រព័ន្ធអនឡាញ ឬតាមរយៈ app និងសារជាអក្សរ)<br>• រៀបចំឯកសារទស្សនទានស្តីពីយុទ្ធនាការនេះ (ឧទាហរណ៍ គោលដៅ ក្រុមមុខសញ្ញា លទ្ធផលដែលចង់បាន) សរសេរខ្លឹមសារដោយសង្ខេប<br>• កំណត់រក និងទាក់ទងភាគីដែលមានសក្តានុពលអនុវត្តតាមទស្សនទាន ស្តីពីការរៀបចំយុទ្ធនាការនេះ (ឧទាហរណ៍ ទាក់ទងទៅកាន់ក្រុមហ៊ុនផ្សាយពាណិជ្ជកម្ម ដើម្បីរៀបចំយុទ្ធនាការ/ការផ្សាយពាណិជ្ជកម្មដោយគិតថ្លៃត្រឹមថ្លៃដើម)<br>• អនុវត្តយុទ្ធនាការ និងវាស់វែងលទ្ធផល និងផលដែលបានមកវិញពីការវិនិយោគ (ROI)<br>• ផលិត និងផ្សព្វផ្សាយសៀវភៅ "អាហារក្នុងស្រុកដែលសម្បូរដោយជីវជាតិចិញ្ចឹម<br>• គាំទ្រការបញ្ចូលការអប់រំអំពីអាហារូបត្ថម្ភទៅក្នុងកម្មវិធីសិក្សា និងកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល<br>• រៀបចំការប្រកួតប្រជែង និងផ្តល់រង្វាន់ដល់យុទ្ធនាការដែលផ្តល់ការទាក់ទាញការចូលរួមបានច្រើនជាងគេដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរតម្រូវការរបស់អ្នកប្រើប្រាស់ (អាចធ្វើដោយសហការជាមួយនឹងអ្នកឧបត្ថម្ភដែលមានសក្តានុពល)<br>• បង្កើនការយល់ដឹងរបស់អ្នកប្រើប្រាស់អំពីសំណល់អាហារ ឧ. ការរៀបចំផែនការអាហារជាដើម | H សមាជិក<br>H អ្នកប្រើប្រាស់<br>H ទីផ្សារ<br>H ស្ថានភាពអាហារូបត្ថម្ភ |

# សសរស្តម្ភជាយុទ្ធសាស្ត្រទី ២-សូចនាករប្រតិបត្តិការគន្លឹះ

## បង្កើនការយល់ដឹងពីអាហារូបត្ថម្ភ និងតម្រូវការអាហារសម្បូរជីវជាតិ

| របៀបអាន | ដឹកនាំ | គាំទ្រ | | | |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ៥ |

ការផ្តោតសំខាន់របស់យើងនៅទីនេះ: ដឹកនាំ / គាំទ្រ

"ក្រុមការងារ SBN សម្របសម្រួលគំនិតផ្តួចផ្តើមទាំងនេះ និងបានទទួលការគាំទ្រនៅកម្រិតផ្សេងៗ ពីអ្នកផ្តល់ជំនួយ ដៃគូ និងសមាជិក"

### សូចនាករប្រតិបត្តិការគន្លឹះ ផ្ទាល់ – វង្វាស់ភាពជោគជ័យសម្រាប់បណ្តាញ

| សូចនាករប្រតិបត្តិការគន្លឹះ | សេចក្តីពិពណ៌នា | រយៈពេល |
|---|---|---|
| ឯកសារទស្សនទានយ៉ាងតិច ១ ត្រូវបានរៀបចំឡើង និងចែករំលែកជារៀងរាល់ឆ្នាំ | • រៀបចំឯកសារទស្សនទានយ៉ាងតិចណាស់ចំនួន ១ ស្តីពីការរៀបចំយុទ្ធនាការបង្កើនការយល់ដឹងអំពីអាហារូបត្ថម្ភ/SBCC<br>• ទទួលមតិត្រឡប់ពីតួអង្គពាក់ព័ន្ធ មុនពេលទាក់ទងទៅកាន់ដៃគូអនុវត្តដែលមានសក្តានុពល | ត្រឹមចុងឆ្នាំ ២០២៣ (នឹងត្រូវពិនិត្យឡើងវិញនៅក្នុងឆ្នាំ ២០២៤) |
| ដៃគូសក្តានុពលយ៉ាងតិច ៥ ត្រូវបានកំណត់ និងជួបប្រាស្រ័យទាក់ទងជារៀងរាល់ឆ្នាំ | • ទាក់ទងជាផ្លូវការទៅកាន់ក្រុមហ៊ុនឧបត្ថម្ភ/ដៃគូអភិវឌ្ឍន៍យ៉ាងតិចណាស់ចំនួន ៥ ដោយភ្ជាប់ឯកសារទស្សនទានខាងលើ ដើម្បីរៀបំយុទ្ធនាការ SBCC / បង្កើនការយល់ដឹងអំពីអាហារូបត្ថម្ភ<br>• ផ្តោតលើក្រុមហ៊ុនឯកជន អ្នកផ្តល់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលជាដៃគូ | ត្រឹមចុងឆ្នាំ ២០២៣ |
| ផ្តល់ការគាំទ្រដល់ការអនុវត្តស្លាកសញ្ញាផលិតផលអាហារូបត្ថម្ភបានចំនួន ១ | • ដើម្បីផ្តល់ការគាំទ្រដល់ការផ្សព្វផ្សាយស្លាកសញ្ញា ដែលគាំទ្រដល់អាហារូបត្ថម្ភដែលសមស្រប | ត្រឹមចុងឆ្នាំ ២០២៥ |
| យុទ្ធនាការបង្កើនការយល់ដឹងពីអាហារូបត្ថម្ភ/SBCC ចំនួន ២ បានទទួលថវិកាគាំទ្រ និងអនុវត្ត | • ដើម្បីរៀបចំយុទ្ធនាការបង្កើនការយល់ដឹងអំពីអាហារូបត្ថម្ភ/SBCC ធំៗ ចំនួន ២ ប្រកបដោយជោគជ័យ (តាមរយៈការធ្វើការងាររួមគ្នាជាដៃគូ) ក្នុងគោលបំណងបង្កើនតម្រូវការ និងការបរិភោគអាហារដែលសម្បូរជីវជាតិ | ត្រឹមចុងឆ្នាំ ២០២៥ |

### សូចនាករប្រតិបត្តិការគន្លឹះ ប្រយោល – លទ្ធផលចុងក្រោយដែលចង់សម្រេចបាន ឬអត្ថប្រយោជន៍ដែលគំនិតផ្តួចផ្តើមជាអាទិភាពត្រូវបានរៀបចំឡើង ដើម្បីសម្រេច

| សូចនាករប្រតិបត្តិការគន្លឹះ | សេចក្តីពិពណ៌នា | រយៈពេល |
|---|---|---|
| ការយល់ដឹងរបស់អ្នកប្រើប្រាស់អំពីសារៈសំខាន់នៃរបបអាហារសុខភាព និងការអនុវត្តដែលលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភមានការកើនឡើង | • ផ្លាស់ប្តូរទម្លាប់ទទួលទានអាហាររបស់អ្នកប្រើប្រាស់ ដើម្បីឱ្យពួកគេងាកទៅរកអាហារ និងផលិតផលដែលសម្បូរជីវជាតិ | ត្រឹមចុងឆ្នាំ ២០២៥ |
| ផលិតផលអាហារដែលសម្បូរជីវជាតិមានច្រើននៅលើទីផ្សារ និងជាអាហារដែលអ្នកប្រើប្រាស់ចង់បាន | • ការផ្លាស់ប្តូរ ការយល់ឃើញរបស់អ្នកប្រើប្រាស់លើផលិតផលដែលបញ្ចូលមីក្រូសារជាតិ<br>• អាហារ និងផលិតផលសម្បូរជីវជាតិដែលផលិតនៅក្នុងស្រុកបានទទួលការផ្សព្វផ្សាយកាន់តែទូលំទូលាយ និងក្លាយជាផលិតផលដែលអតិថិជនចង់បាន | ត្រឹមចុងឆ្នាំ ២០២៥ |
| តម្រូវការជាលក្ខណៈពាណិជ្ជកម្មនូវផលិតផលអាហារដែលសម្បូរជីវជាតិមានការកើនឡើង | • នៅពេលដែលមានអតិថិជនកាន់តែច្រើនត្រូវការអាហារដែលសម្បូរជីវជាតិ ទំហំទីផ្សារ ផលិតផលដែលសម្បូរជីវជាតិ ដែលផលិតសម្រាប់គោលបំណងពាណិជ្ជកម្មកាន់តែមានការកើនឡើង និងអាចជាកត្តាទាក់ទាញក្រុមហ៊ុនកាន់តែច្រើនឱ្យចូលរួមនៅក្នុងការផលិតនូវផលិតផលបែបនេះ | ត្រឹមចុងឆ្នាំ ២០២៥ |

| របៀបអាន | ដឹកនាំ | គាំទ្រ | | | |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ៥ |

| ការផ្ដោតសំខាន់របស់យើងនៅទីនេះ | ដឹកនាំ | |
|---|---|---|
| | គាំទ្រ | "ក្រុមការងារ SBN សម្របសម្រួលគំនិតផ្ដួចផ្ដើមទាំងនេះ និងបានទទួលការគាំទ្រនៅកម្រិតផ្សេងៗ ពីអ្នកផ្ដល់ជំនួយ ដៃគូ និងសមាជិក" |

# សសរស្តម្ភជាយុទ្ធសាស្ត្រទី ៣ - គំនិតផ្ដួចផ្ដើម

## បង្កើនការផ្គត់ផ្គង់ផលិតផលអាហារដែលសម្បូរជីវជាតិ និងផលិតផលអាហារដែលបញ្ចូលមីក្រូសារជាតិ

| គំនិតផ្ដួចផ្ដើម | សកម្មភាព | ដោយរបៀបណា | ផលជះ |
|---|---|---|---|
| ៣.១<br>ផ្ដល់ដំបូន្មាន, ការណែនាំ, ការបណ្ដុះបណ្ដាល និងឧបករណ៍ ដើម្បីបង្កើនការចូលរួមរបស់វិស័យពាណិជ្ជកម្មនៅក្នុងអាហារូបត្ថម្ភ, ដូចជាដោយសហគ្រាសធុនតូច និងមធ្យម អាជីវកម្មដឹកនាំដោយស្ត្រីជាដើម | • ផ្ដល់ការគាំទ្រផ្នែកអភិវឌ្ឍន៍ធុរកិច្ច ក្នុងទម្រង់ជាសិក្ខាសាលា ព្រឹត្តិការណ៍វេទិកាធុរកិច្ច ការបណ្ដុះបណ្ដាល ឯកសារផ្ដល់ការណែនាំអំពីអាជីវកម្ម និងឧបករណ៍ សម្រាប់អនុវត្ត<br>• ធានាឱ្យមានការយកចិត្តទុកដាក់ លើតម្រូវការចំណេះដឹង និងព័ត៌មានរបស់សមាជិក | • កំណត់ពីបញ្ហាខ្វះខាតចំណេះដឹងសំខាន់ៗ របស់សមាជិក SBN កម្ពុជា និងការគាំទ្របច្ចេកទេសដែលពួកគេត្រូវការ។ ចំណុចខ្វះខាតទាំងនេះអាចពាក់ព័ន្ធនឹង ការអភិវឌ្ឍ/ការបង្កើនផលិតផល គុណភាព និងសុវត្ថិភាពអាហារ ។ល។ ប៉ុន្តែក៏អាចបញ្ចូលការគាំទ្រទូទៅសម្រាប់អាជីវកម្មផងដែរ (ឧ. គណនេយ្យជាដើម)<br>• ធ្វើការកំណត់ និងអនុវត្តយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាព សម្រាប់ផ្ដល់ដំបូន្មាន ការណែនាំ ឬការបណ្ដុះបណ្ដាលដែលផ្ដោតលើចំណេះដឹងដែលត្រូវបានកំណត់ថានៅមានភាពខ្វះខាត (ឧទាហរណ៍ អញ្ជើញឱ្យក្រុមហ៊ុននាំមុខនៅក្នុងឧស្សាហកម្ម ឬអ្នកជំនាញ បច្ចេកទេស ដែលអាចចូលរួមនៅក្នុងសិក្ខាសាលា ឬព្រឹត្តិការណ៍ចងក្រងបណ្ដាញ ឬរៀបចំការស្រាវជ្រាវ ដើម្បីប្រមូលព័ត៌មានសម្រាប់រៀបចំឯកសារណែនាំសម្រាប់អាជីវកម្ម ដោយផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងអ្នកផ្ដល់សេវា ដំណើរទស្សនកិច្ចសិក្សា ។ល។)<br>• កំណត់រកតម្រូវការជំនួយបច្ចេកទេស និងធនធានហិរញ្ញវត្ថុជាក់លាក់ របស់ SME និងសហគ្រិនជាស្ត្រី<br>• រៀបចំបង្កើត និងផ្សព្វផ្សាយនូវឧបករណ៍គាំទ្រធុរកិច្ច និងទម្រង់គំរូនានា<br>• ផ្ដល់ការកសាងសមត្ថភាព ជំនួយបច្ចេកទេស និងដំណោះស្រាយហិរញ្ញវត្ថុដល់ SME តាមរយៈការសហការជាមួយនឹងដៃគូដទៃទៀត<br>• ទាញប្រយោជន៍ពីចំណេះដឹង និងការអនុវត្តល្អៗ ពី SBN ដទៃទៀតនៅអាស៊ីប៉ាស៊ីហ្វិក តាមរយៈការរៀបចំព្រឹត្តិការណ៍ចែករំលែកបទពិសោធន៍រវាង SBN និងរវាងតួអង្គពាក់ព័ន្ធនានានៅក្នុងតំបន់ | H សមាជិក<br>L អ្នកប្រើប្រាស់<br>M ទីផ្សារ<br>L ស្ថានភាពអាហារូបត្ថម្ភ |
| ៣.២<br>ជម្រុញនវានុវត្តន៍ និងការអភិវឌ្ឍផលិតផលថ្មីៗ ដូចជាផលិតផលអាហារដែលសម្បូរជីវជាតិ និងផលិតផលអាហារដែលបញ្ចូលមីក្រូសារជាតិជាដើម | • ចូលរួមនៅក្នុងកម្មវិធីនវានុវត្តន៍ និងកម្មវិធីអភិវឌ្ឍន៍ផលិតផល ដើម្បីគាំទ្រដល់អាជីវកម្មនានាក្នុងការអភិវឌ្ឍផលិតផលអាហារូបត្ថម្ភថ្មីៗ ផលិតនូវផលិតផលដែលបានបញ្ចូលមីក្រូសារជាតិ និងរៀបចំរូបមន្តថ្មី សម្រាប់ផលិតផលរបស់ខ្លួន ដើម្បីកាត់បន្ថយបរិមាណស្ករ អំបិល និងខ្លាញ់ | • ជាផ្នែកមួយនៃកិច្ចប្រជុំ របស់SBN ដែលរៀបចំជាទៀងទាត់ជាមួយនឹងសមាជិក ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងតួអង្គពាក់ព័ន្ធដទៃទៀត ធ្វើការវាយតម្លៃលើឱកាសចូលរួមក្នុងកម្មវិធីនវានុវត្តន៍ និងកម្មវិធីអភិវឌ្ឍន៍ផលិតផលថ្មី/បញ្ចូលមីក្រូសារជាតិទៅក្នុងអាហារ/ ការផ្លាស់ប្ដូររូបមន្តផលិតជាដើម<br>• ឧបត្ថម្ភគាំទ្រដល់គំនិតផ្ដួចផ្ដើមនានាពាក់ព័ន្ធទៅនឹងការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ បង្កើនការយល់ដឹងដល់សមាជិក SBN កម្ពុជាអំពីតម្រូវការនៃការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ ព្រមទាំងបរិយាកាសគតិយុត្តិ ចែករំលែកចំណេះដឹង នឹងការអនុវត្តល្អក្នុងវិស័យឧស្សាហកម្ម និងរៀបចំកិច្ចសន្ទនាដោយចំហជាមួយនឹងរាជរដ្ឋាភិបាល<br>• ធ្វើការជាមួយនឹងតួអង្គពាក់ព័ន្ធនានាលើវិស័យនវានុវត្តន៍ និងមជ្ឈមណ្ឌលបង្កើតបច្ចេកវិទ្យា ដើម្បីជំរុញឱ្យមានការអភិវឌ្ឍផលិតផលដែលសម្បូរជីវជាតិ ផលិតក្នុងស្រុកក្នុងតម្លៃសមរម្យ និងដំណោះស្រាយបច្ចេកវិទ្យាសម្រាប់ធ្វើការផ្លាស់ប្ដូរប្រព័ន្ធស្បៀងជាវិជ្ជមាន (ឧ. រៀបចំការប្រកួតប្រជែង ឧបត្ថម្ភដល់កម្មវិធីផ្ដល់រង្វាន់ ផ្ដល់លទ្ធភាពឱ្យជ័យលាភីចូលរួមក្នុងកម្មវិធី boot camps, ភ្ជាប់ទំនាក់ទំនងរវាងអាជីវកម្មជាមួយនឹងស្ថាប័នសិក្សាស្រាវជ្រាវ។ល។) | M សមាជិក<br>M អ្នកប្រើប្រាស់<br>M ទីផ្សារ<br>L ស្ថានភាពអាហារូបត្ថម្ភ |

| គំនិតផ្តួចផ្តើម | សកម្មភាព | ដោយរបៀបណា | ផលជះ |
|---|---|---|---|
| ៣.៣<br>បង្កើនភាពអាចរកបាននូវផលិតផលអាហារដែលសម្បូរជីវជាតិ និងអាហារដែលបញ្ចូលមីក្រូសារជាតិនៅតាមកន្លែងលក់រាយ | • លើកទឹកចិត្តឱ្យមានការបង្កើនការលក់រាយ និងការលក់អាហារសម្បូរជីវជាតិ ដែលផលិតក្នុងស្រុក ផលិតផលបញ្ចូលមីក្រូសារជាតិ និងអាហារបន្ថែម | • សម្របសម្រួលជាមួយនឹងក្រុមហ៊ុនលក់រាយ ដើម្បីផ្សព្វផ្សាយអំពីអាហារសម្បូរជីវជាតិ ដែលផលិតនៅក្នុងស្រុក និងផលិតផលបញ្ចូលមីក្រូសារជាតិ ការផ្សព្វផ្សាយនៅក្នុងហាង "កម្មវិធីជជែកអំពីសុខភាព" ព្រឹត្តិការណ៍តាំងលក់ ការផ្តល់ផលិតផលគំរូដោយមិនគិតថ្លៃ ការផ្តល់គូប៉ុង (coupons) ។ល។<br>• សម្របសម្រួលជាមួយនឹងក្រុមហ៊ុនលក់គ្រឿងទេសតាមអនឡាញ ដើម្បីបញ្ចូលផលិតផលអាហារដែលសម្បូរជីវជាតិ និងផលិតអាហារបញ្ចូលមីក្រូសារជាតិ លើវេទិការបស់ពួកគេ និងផ្សព្វផ្សាយពីផលិតផលទាំងនេះ<br>• ធ្វើការងារជាមួយនឹងក្រុមហ៊ុនបច្ចេកវិទ្យាព័ត៌មាន ដើម្បីបង្កើតទំនាក់ទំនងជាមួយនឹងទីផ្សារ ប្រើប្រាស់វេទិកាអនឡាញដែលមានស្រាប់ ដើម្បីដឹកជញ្ជូនអាហារពីកសិករទៅដល់អ្នកប្រើប្រាស់<br>• ធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងក្រុមហ៊ុនដឹកជញ្ជូនអាហារដើម្បីជំរុញការលក់អាហារដែលសម្បូរជីវជាតិ | H សមាជិក<br>H អ្នកប្រើប្រាស់<br>H ទីផ្សារ<br>H ស្ថានភាពអាហារូបត្ថម្ភ |
| ៣.៤<br>បង្កើន និងសម្រួលឱ្យសមាជិកអាចទទួលបានជំនួយហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសជាមួយនឹងការផ្តោតពិសេសលើ SME និងអាជីវកម្មដឹកនាំដោយស្ត្រី | • ជួយឱ្យសមាជិកទទួលបាននូវថវិកា និងជំនួយបច្ចេកទេសពីសមាជិក Global SBN ធនាគារពហុភាគី និងធនាគារជាតិ អ្នកផ្តល់ជំនួយ អង្គការក្រៅរដ្ឋាភិបាលសកល មូលនិធិសប្បុរសធម៌ និងដៃគូដទៃទៀត | • កំណត់ពីឱកាស ដើម្បីអាចទទួលបានជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ និងចែករំលែកឱកាសនេះជាមួយនឹងសមាជិកបណ្តាញ ដូចជាធនាគារជាតិ មូលនិធិឯកជន ស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍។ល។<br>• ផ្តល់ការណែនាំ និងតភ្ជាប់ទំនាក់ទំនងជាមួយនឹងសមាជិកនៃ Global SBN ដើម្បីទទួលបានជំនួយបច្ចេកទេសពីសមាជិកទាំងនោះ<br>• លើកទឹកចិត្តឱ្យសមាជិកស្នើសុំការគាំទ្រពី SBN ដើម្បីដាក់ពាក្យសុំជំនួយហិរញ្ញវត្ថុ និងជំនួយបច្ចេកទេស<br>និងជួយរៀបចំសំណើ ដើម្បីទទួលបានឱកាសទាំងនេះតាមរយៈរបៀបវារៈអប់រំផ្សព្វផ្សាយរបស់ SBN | H សមាជិក<br>L អ្នកប្រើប្រាស់<br>M ទីផ្សារ<br>L ស្ថានភាពអាហារូបត្ថម្ភ |

# សសរស្តម្ភជាយុទ្ធសាស្ត្រទី ៣-សូចនាករប្រតិបត្តិការគន្លឹះ

## បង្កើនការផ្គត់ផ្គង់ផលិតផលអាហារដែលសម្បូរជីវជាតិ និងផលិតផលអាហារដែលបញ្ចូលមីក្រូសារជាតិ

| របៀបអាន | ដឹកនាំ | គាំទ្រ | | | |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ៥ |

| ការផ្តោតសំខាន់របស់យើងនៅទីនេះ: | |
|---|---|
| ដឹកនាំ | |
| គាំទ្រ | "ក្រុមការងារ SBN សម្របសម្រួលគំនិតផ្តួចផ្តើមទាំងនេះ និងបានទទួលការគាំទ្រនៅកម្រិតផ្សេងៗ ពីអ្នកផ្តល់ជំនួយ ដៃគូ និងសមាជិក" |

### សូចនាករប្រតិបត្តិការគន្លឹះ ផ្ទាល់ – រង្វាស់ភាពជោគជ័យសម្រាប់ SBN

| សូចនាករប្រតិបត្តិការគន្លឹះ | សេចក្តីពិពណ៌នា | រយៈពេល |
|---|---|---|
| ចូលរួមចំណែកក្នុងគំនិតផ្តួចផ្តើមនវានុវត្តន៍/ការអភិវឌ្ឍផលិតផលថ្មី/ការបញ្ចូលមីក្រូសារជាតិ ការកែលម្អរូបមន្តផលិតយ៉ាងតិច ២ ក្នុងមួយឆ្នាំ | • ចូលរួមនៅក្នុងកម្មវិធីនវានុវត្តន៍ កម្មវិធីអភិវឌ្ឍន៍ផលិតផលថ្មី កម្មវិធីសហគ្រិនភាព និងកម្មវិធីបណ្តុះធុរកិច្ចពាក់ព័ន្ធនឹងអាហារូបត្ថម្ភយ៉ាងតិចណាស់មួយជារៀងរាល់ឆ្នាំ<br>• ចូលរួមក្នុងគំនិតផ្តួចផ្តើមបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារ និងគំនិតផ្តួចផ្តើមផ្លាស់ប្តូររូបមន្ត (ជាថ្មី) សម្រាប់ផលិតផលយ៉ាងតិចណាស់ចំនួនមួយជារៀងរាល់ឆ្នាំ | ត្រឹមចុងឆ្នាំ ២០២២ (នឹងត្រូវពិនិត្យឡើងវិញនៅក្នុងឆ្នាំ ២០២៣) |
| សិក្ខាសាលាចែករំលែកការអនុវត្តល្អ ចំនួន ១ លើកក្នុង ១ ឆ្នាំ | • រៀបចំសិក្ខាសាលាជាមួយនឹងSBN ដទៃទៀតក្នុងតំបន់ ដើម្បីចែករំលែកចំណេះដឹងនិងបទពិសោធន៍ក្នុងចំណោមតួអង្គ ពាក់ព័ន្ធនានា ស្តីពីការអនុវត្តគំនិតផ្តួចផ្តើមអាហារូបត្ថម្ភ (ឧ. ការបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារ កម្មវិធីលើកកម្ពស់អាហារូបត្ថម្ភសម្រាប់កម្មករនិយោជិតនៅក្នុងវិស័យកាត់ដេរ។ល។) | ត្រឹមចុងឆ្នាំ ២០២៥ |
| ព្រឹត្តិការណ៍ប្រចាំឆ្នាំយ៉ាងតិចចំនួន ៦ | • ដូចក្នុងគំនិតផ្តួចផ្តើម ១.២ និង ៣.១ ធ្វើផែនការនឹងសម្របសម្រួលរៀបចំព្រឹត្តិការណ៍ចំនួនយ៉ាងតិច ៦ ក្នុងមួយឆ្នាំ ដើម្បីលើកកម្ពស់ និងផ្តល់ចំណេះដឹងដល់សមាជិក បង្កើតឱកាសទំនាក់ទំនងដល់សមាជិក នឹងចែករំលែកព័ត៌មានបច្ចុប្បន្នភាព និងសកម្មភាពនានារបស់បណ្តាញ<br>• រៀបចំព្រឹត្តិការណ៍សម្រាប់ SME យ៉ាងតិចណាស់ចំនួន ១ ក្នុងមួយឆ្នាំ | ត្រឹមចុងឆ្នាំ ២០២៥ |
| យ៉ាងតិចមានអង្គភាពលក់រាយ ១ ត្រូវបានទាក់ទងឱ្យចូលរួមក្នុងសកម្មភាពអាហារូបត្ថម្ភជារៀងរាល់ឆ្នាំ | • ជំរុញការចូលរួមពីក្រុមហ៊ុនលក់រាយធំៗ យ៉ាងតិចណាស់ចំនួន ១ ក្នុងការផ្សព្វផ្សាយផលិតផលសម្បូរជីវជាតិដែលផលិតនៅក្នុងស្រុក និងផលិតផលដែលបញ្ចូលមីក្រូសារជាតិ និងផ្សព្វផ្សាយពីរបបអាហារសុខភាពជាទូទៅ | ត្រឹមចុងឆ្នាំ ២០២២ (នឹងត្រូវពិនិត្យឡើងវិញនៅក្នុងឆ្នាំ ២០២៣) |
| សំណើគម្រោងយ៉ាងតិច ៥ ទទួលបានការគាំទ្រជាជំនួយបច្ចេកទេស/ថវិកា | • ផ្តល់ការគាំទ្រដល់សមាជិកក្នុងការរៀបចំគម្រោងសំណើ ចំនួន ៥ (ការគាំទ្រកម្រិតមូលដ្ឋាន ឬការគាំទ្រកម្រិតស៊ីជម្រៅ) ជារៀងរាល់ឆ្នាំ ដើម្បីជួយ ឱ្យគាត់មានលទ្ធភាពខ្ពស់ក្នុងការទទួលបានថវិកាគាំទ្រ និងជំនួយបច្ចេកទេសសម្រាប់គំនិតផ្តួចផ្តើមពាក់ព័ន្ធនឹងអាហារូបត្ថម្ភ ពាក់ព័ន្ធនឹងចំណុចនេះសំណើយ៉ាងតិចណាស់ ចំនួន ៣ គួរជាសំណើ សម្រាប់ SME និង ១ ជាសំណើសម្រាប់អាជីវកម្មដែលដឹកនាំដោយស្ត្រី | ត្រឹមចុងឆ្នាំ ២០២២ (នឹងត្រូវពិនិត្យឡើងវិញនៅក្នុងឆ្នាំ ២០២៣) |

## សូចនាករប្រតិបត្តិការគន្លឹះ ប្រយោល – លទ្ធផលចុងក្រោយដែលចង់សម្រេចបាន ឬអត្ថប្រយោជន៍ដែលគំនិតផ្តួចផ្តើមជាអាទិភាពត្រូវបានរៀបចំឡើង ដើម្បីសម្រេច

| សូចនាករប្រតិបត្តិការគន្លឹះ | សេចក្តីពិពណ៌នា | រយៈពេល |
|---|---|---|
| ការលក់ និងភាពចម្រុះនៃផលិតផលអាហារដែលសម្បូរជីវជាតិមានការកើនឡើង | • ទំហំទីផ្សារអាហារូបត្ថម្ភត្រូវបានពង្រីក<br>• មានតួអង្គពាក់ព័ន្ធបន្ថែមទៀត នឹងមានផលិតផលចម្រុះនៅក្នុងទីផ្សារអាហារ និងភេជ្ជៈ | ត្រឹមចុងឆ្នាំ ២០២៥ |
| អ្នកប្រើប្រាស់ទទួលនូវការផ្សព្វផ្សាយពី និងភាពអាចរកបាននូវផលិតផលអាហារដែលសម្បូរជីវជាតិ និងផលិតផលអាហារបញ្ចូលមីក្រូសារជាតិមានការកើនឡើង | • មានផលិតផលដែលសម្បូរជីវជាតិ និងផលិតផលបញ្ចូលមីក្រូសារជាតិ កាន់តែច្រើនសម្រាប់អតិថិជននៅគ្រប់តំបន់នៃប្រទេសកម្ពុជា សម្រាប់ប្រជាជននៅគ្រប់កម្រិតនៃប្រាក់ចំណូល<br>• ផលិតផលដែលសម្បូរជីវជាតិ អាចរកបានកាន់តែងាយស្រួល ត្រូវបានចែកចាយយ៉ាងទូលំទូលាយ និងទទួលបានការផ្សព្វផ្សាយកាន់តែច្រើននៅតាមកន្លែងលក់រាយ (នៅតាមហាង និងតាមប្រព័ន្ធអនឡាញ) | ត្រឹមចុងឆ្នាំ ២០២៥ |
| សហគ្រាសខ្នាតតូច និងមធ្យម និងអាជីវកម្មដឹកនាំដោយស្ត្រីរួមចំណែកលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ | • SME និងអាជីវកម្មដែលមានស្ត្រីជាម្ចាស់ ឬជាអ្នកដឹកនាំ ត្រូវបានផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងវិនិយោគិន អ្នកផ្តល់ជំនួយបច្ចេកទេស (រាប់បញ្ចូលទាំងក្រុមហ៊ុនពហុជាតិ) និងគ្រឹះស្ថានហិរញ្ញវត្ថុ និងមានការបង្កើនសមត្ថភាព និងមានការបង្កើនសមត្ថភាពសហគ្រាសទាំងនេះ ក្នុងការផ្គត់ផ្គង់អាហារដែលមានសុវត្ថិភាព និងសម្បូរជីវជាតិ | ត្រឹមចុងឆ្នាំ ២០២៥ |

| របៀបអាន | ដឹកនាំ | គាំទ្រ | | | |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ៥ |

| ការផ្តោតសំខាន់របស់យើងនៅទីនេះ | |
|---|---|
| ដឹកនាំ | |
| គាំទ្រ | "ក្រុមការងារ SBN សម្របសម្រួលគំនិតផ្តួចផ្តើមទាំងនេះ និងបានទទួលការគាំទ្រនៅកម្រិតផ្សេងៗ ពីអ្នកផ្តល់ជំនួយ ដៃគូ និងសមាជិក" |

# សសរស្តម្ភជាយុទ្ធសាស្ត្រទី ៤ - គំនិតផ្តួចផ្តើម

## ពង្រឹងបរិយាកាសអំណោយផល ដើម្បីលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ

| គំនិតផ្តួចផ្តើម | សកម្មភាព | ដោយរបៀបណា | ផលជះ |
|---|---|---|---|
| ៤.១<br>ជំរុញឱ្យមានការរៀបចំជាស្តង់ដារ លិខិតបទដ្ឋានគតិយុត្តិ ច្បាប់ គោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ | • សំយោគ និងកំណត់អាទិភាពលើបញ្ហារបស់វិស័យឯកជន បញ្ហាប្រឈម ឱកាស និងអនុសាសន៍ ដើម្បីធ្វើការចែករំលែកជាមួយនឹងអ្នកធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗក្នុងរាជរដ្ឋាភិបាល | • តាមរយៈកិច្ចប្រជុំ ដែលរៀបចំជាទៀងទាត់ ការអប់រំផ្សព្វផ្សាយ និងការស្នើសុំធាតុចូលបន្តកត់ត្រាអំពីបញ្ហា ការប្រឈម ឱកាស និងអនុសាសន៍សម្រាប់ធ្វើការផ្លាស់ប្តូរសំខាន់របស់វិស័យឯកជន<br>• សំយោគបញ្ហាដែលសមស្របដើម្បីសុំការឆ្លើយតបពីរាជរដ្ឋាភិបាល និងចែករំលែកដល់សមាជិកសំខាន់ៗ មកពីវិស័យឯកជន ដើម្បីសុំធាតុចូលរបស់ពួកគេ<br>• ចែករំលែកព័ត៌មាន ជាមួយនឹងអ្នកធ្វើសេចក្តីសម្រេចចិត្ត ក្នុងជួររាជរដ្ឋាភិបាលតាមរយៈការរៀបចំឯកសារស្ថានភាព និងកិច្ចប្រជុំ រួមនឹងព្រឹត្តិការណ៍តុមូលប្រចាំឆ្នាំ<br>• ផ្តល់ការគាំទ្រដល់ការអនុម័តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ ស្តីពីសុវត្ថិភាពអាហារ<br>• ផ្តល់ជូនសមាជិក SBN អំពីការផ្លាស់ប្តូរគោលនយោបាយពាក់ព័ន្ធថ្មីៗ | H សមាជិក<br>M អ្នកប្រើប្រាស់<br>M ទីផ្សារ<br>L ស្ថានភាពអាហារូបត្ថម្ភ |
| ៤.២<br>ផ្តល់ធាតុចូលអនុសាសន៍ដល់រាជរដ្ឋាភិបាល វិស័យឯកជនអំពីការបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារ | • បញ្ជាក់ឱ្យបានច្បាស់ពីគោលជំហររបស់រាជរដ្ឋាភិបាលជុំវិញការបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារដែលកំណត់ដោយច្បាប់ ធ្វើឡើងដោយស្ម័គ្រចិត្ត និងបញ្ចូលទៅក្នុងកម្មវិធីសំណាញ់សុវត្ថិភាពសង្គម (ដោយប្រើប្រាស់អភិក្រមផ្តោតលើទីតាំង) | • សំយោគការយល់ឃើញរបស់វិស័យឯកជន ស្តីពីការបញ្ចូលមីក្រូសារជាតិបែបចាប់បង្ខំដោយច្បាប់ និងបែបស្ម័គ្រចិត្ត និងចែករំលែកទស្សនៈយល់ឃើញនេះជាមួយនឹង ក.ក.ជ.<br>• ចូលរួមនៅក្នុងអនុគណៈកម្មការជាតិបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ (NSCFF) និងចូលរួមកិច្ចប្រជុំ ដើម្បីកំណត់ពីតួនាទីរបស់វិស័យឯកជននៅក្នុងការបញ្ចូលមីក្រូសារជាតិទៅក្នុងអង្ករ និងបង្ហាញពីចំណាប់អារម្មណ៍របស់វិស័យឯកជន។ ចែករំលែកអំពីចក្ខុវិស័យជាយុទ្ធសាស្ត្រ ស្តីពីការបញ្ចូលមីក្រូសារជាតិទៅក្នុងអង្ករនៅកម្ពុជា និងតម្លៃបន្ថែមនៃកម្មវិធីនេះ ដែលត្រូវបានចាត់ទុកថាជាយុទ្ធសាស្ត្រដើម្បីឆ្លើយតបចំពោះបញ្ហាកង្វះមីក្រូសារជាតិ | M សមាជិក<br>M អ្នកប្រើប្រាស់<br>M ទីផ្សារ<br>H ស្ថានភាពអាហារូបត្ថម្ភ |

| គំនិតផ្តួចផ្តើម | សកម្មភាព | ដោយរបៀបណា | ផលជះ |
|---|---|---|---|
| | • ជំរុញឱ្យមានការពង្រីកការបញ្ចូលមីក្រូសារជាតិទៅក្នុងអង្ករ និងចំណីអាហារ<br>• រៀបចំ និងបង្ហាញ ផែនទីបង្ហាញផ្លូវស្តីពីការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ ស្តង់ដារ នឹងរៀបចំគោលនយោបាយដែលមានលក្ខណៈប្រទាក់ក្រឡាគ្នាស្តីពីការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ | • ធ្វើការជាមួយនឹងក្រុមឧស្សាហកម្មដែលពាក់ព័ន្ធ ក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូសហប្រជាជាតិ គាំទ្រដល់ការរៀបចំឯកសារណែនាំបច្ចេកទេស និងគោលនយោបាយស្បៀង ក្របខ័ណ្ឌគតិយុត្តិ និងច្បាប់សម្រាប់អាហារដែលមានបញ្ចូលមីក្រូសារជាតិ និងជំរុញឱ្យមានការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ ដែលចូលជាធរមានឱ្យមានប្រសិទ្ធភាព<br>• សហការជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ និង ក្រសួងពាណិជ្ជកម្ម ផ្តល់ការគាំទ្រដល់ការរៀបចំស្តង់ដារគ្រាប់អង្ករមីក្រូសារជាតិ អង្ករដែលមានបញ្ចូលមីក្រូសារជាតិ យន្តការត្រួតពិនិត្យមូលដ្ឋានផលិតអង្ករដែលមានបញ្ចូលមីក្រូសារជាតិ ប្រព័ន្ធចុះបញ្ជិការផលិតផល យន្តការអធិការកិច្ចនិងត្រួតពិនិត្យសម្រាប់ការនាំចូលនិងនាំចេញគ្រាប់អង្ករមីក្រូសារជាតិនិងអង្ករដែលមានបញ្ចូលមីក្រូសារជាតិ | |
| ៤.៣<br>ផ្តោតការយកចិត្តទុកដាក់លើគោលនយោបាយ និងការស្វែងរកការគាំទ្រដើម្បីដោះស្រាយបន្ទុកទ្វេនៃបញ្ហាអាហារូបត្ថម្ភ និងជំងឺមិនឆ្លង | ជម្រុញឱ្យមានការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តិផ្អែកលើភស្តុតាង ដើម្បីកាត់បន្ថយការប្រើប្រាស់អាហារ និងភេសជ្ជៈ ដែលប៉ះពាល់សុខភាព | • សំយោគការស្រាវជ្រាវដែលមានស្រាប់ និងចែករំលែកបទពិសោធន៍ពីប្រទេសដទៃទៀតក្នុងកិច្ចប្រជុំតុមូលប្រចាំឆ្នាំ ដើម្បីជំរុញឱ្យអ្នកតាក់តែងគោលនយោបាយឱ្យ ទីមួយ- អនុម័តច្បាប់ដើម្បីកាត់បន្ថយបរិមាណស្ករ ខ្លាញ់ និងអំបិលដែលមានកម្រិតខ្ពស់នៅក្នុងអាហារនិងភេជ្ជៈកែច្នៃ ទីពី- ដាក់ឱ្យអនុវត្តនូវការត្រួតពិនិត្យការផ្សព្វផ្សាយ អាហារប៉ះពាល់សុខភាពដល់កុមារ ទីបី- ផ្តល់ការលើកទឹកចិត្ត ឱ្យមានការស្រាវជ្រាវនិងអភិវឌ្ឍ ដើម្បីឱ្យអាជីវកម្មអាចរៀបចំរូបមន្តផលិត ផលិតផលទ្រទ្រង់សុខភាព ទីបួន- ផ្តល់ការលើកទឹកចិត្តដល់កន្លែងលក់អាហារ ដើម្បីបង្កើតនូវជម្រើសអាហារទ្រទ្រង់សុខភាព ទីប្រាំ- អនុម័តស្តង់ដារអាហារ និងអាហារូបត្ថម្ភសម្រាប់ប្រើប្រាស់ក្នុងគ្រឹះស្ថានសាធារណៈ (ឧទាហរណ៍ មន្ទីរពេទ្យ ។ល។) ទីប្រាំមួយ- ធានាឱ្យមានការផ្តល់ការបណ្តុះបណ្តាលគ្រប់គ្រាន់ដល់បុគ្គលិកសុខាភិបាល ដើម្បីបង្ការ រកឱ្យឃើញ និងព្យាបាលបញ្ហាអាហារូបត្ថម្ភគ្រប់ទម្រង់<br>• ជំរុញភាពជាដៃគូរវាងរដ្ឋ និងឯកជន ដើម្បីគាំទ្រដល់ការផលិតអាហារទ្រទ្រង់សុខភាព និងងាយស្រួលរកបាន | M សមាជិក<br>M អ្នកប្រើប្រាស់<br>M ទីផ្សារ<br>H ស្ថានភាពអាហារូបត្ថម្ភ |

# សសរស្តម្ភជាយុទ្ធសាស្ត្រទី ៤-សូចនាករប្រតិបត្តិការគន្លឹះ

## ពង្រឹងបរិយាកាសអំណោយផល ដើម្បីលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ

| របៀបអាន | ដឹកនាំ | គាំទ្រ | | | |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ៥ |

| ការផ្តោតសំខាន់របស់យើងនៅទីនេះ | ដឹកនាំ | |
|---|---|---|
| | គាំទ្រ | “ក្រុមការងារ SBN សម្របសម្រួលគំនិតផ្តួចផ្តើមទាំងនេះ និងបានទទួលការគាំទ្រនៅកម្រិតផ្សេងៗ ពីអ្នកផ្តល់ជំនួយ ដៃគូ និងសមាជិក” |

### សូចនាករប្រតិបត្តិការគន្លឹះ ផ្ទាល់ – រង្វាស់សមិទ្ធកម្មសម្រាប់ក្រុមការងារ SBN

| សូចនាករប្រតិបត្តិការគន្លឹះ | សេចក្តីពិពណ៌នា | រយៈពេល |
|---|---|---|
| ឯកសារស្តីពីស្ថានភាពរបស់វិស័យឯកជន ក្នុងសកម្មភាពអាហារូបត្ថម្ភចំនួន ១ ត្រូវបានចេញផ្សាយជារៀងរាល់ឆ្នាំ | • ប្រើប្រាស់បញ្ជីដូចរៀបរាប់នៅក្នុងគំនិតផ្តួចផ្តើម ៤.១ រៀបចំឯកសារស្តីពីស្ថានភាពប្រចាំឆ្នាំដោយសង្ខេបអំពីបញ្ហាការប្រឈម ឱកាស និងអនុសាសន៍សំខាន់ៗស្តីពីអាហារូបត្ថម្ភសម្រាប់វិស័យឯកជន<br>• ចែករំលែកឯកសារស្តីពីស្ថានភាព ជាមួយនឹងអ្នកធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចរៀបរាប់នៅក្នុងចំណុច ៤.១ ខាងលើ | ត្រឹមចុងឆ្នាំ ២០២២ (នឹងត្រូវពិនិត្យឡើងវិញនៅក្នុងឆ្នាំ ២០២៣) |
| ព្រឹត្តិការណ៍ ‘តុមូល’ ចំនួន ២ លើកក្នុង ១ ឆ្នាំ ត្រូវបានរៀបចំឡើងជាមួយនឹងអ្នកតាក់តែងគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល | • សម្របសម្រួលព្រឹត្តិការណ៍កិច្ចប្រជុំ ‘តុមូល’ ប្រចាំឆ្នាំចំនួន ២ លើក ដែលមានការចូលរួមពីវិស័យឯកជន អ្នកធ្វើសេចក្តីសម្រេចចិត្ត ផ្នែកអាហារូបត្ថម្ភសំខាន់ៗ ពីវិស័យឯកជន និងរាជរដ្ឋាភិបាល ដើម្បីពិភាក្សាគ្នាដោយចំហពីបញ្ហា ការប្រឈម និងឱកាសនៅក្នុងទីផ្សារអាហារូបត្ថម្ភ<br>• គោលបំណងគឺដើម្បីធានាឱ្យអ្នកពាក់ព័ន្ធក្នុងជួររាជរដ្ឋាភិបាល យល់ដឹងពីការផ្លាស់ប្តូរនានាដែលចាំបាច់ព្រមទាំងដំណោះស្រាយដែលអាចមាន ដើម្បីធ្វើឱ្យបរិយាកាសលើកកម្ពស់អាហារូបត្ថម្ភក្នុងវិស័យឯកជនកាន់តែមានភាពប្រសើរ<br>• ជំរុញឱ្យមានការរៀបចំបរិយាកាសអំណោយផល ដើម្បីលើកទឹកចិត្តឱ្យសហគ្រាសធុនតូច និងមធ្យមធ្វើសកម្មភាព និងវិនិយោគលើអាហារូបត្ថម្ភ | ត្រឹមចុងឆ្នាំ ២០២២ (នឹងត្រូវពិនិត្យឡើងវិញនៅក្នុងឆ្នាំ ២០២៣) |
| ស្តង់ដារស្តីពីការបញ្ចូលមីក្រូសារជាតិទៅក្នុងអង្ករត្រូវបានត្រូវបានដាក់ចេញ | • បង្កើតស្តង់ដារ ស្តីពីការបញ្ចូលមីក្រូសារជាតិទៅក្នុងអង្ករនៅកម្ពុជា ដោយត្រូវកំណត់ពីលក្ខខណ្ឌ និងគុណភាព និងបរិមាណសារធាតុចិញ្ចឹម<br>• កំណត់យហាប្រភេទស្តីពីការបញ្ចូលមីក្រូសារជាតិទៅក្នុងអង្ករ ដូចជាប្រភេទអង្ករ បច្ចេកវិទ្យាដែលប្រើប្រាស់ផលធៀបគ្រាប់អង្ករមីក្រូសារជាតិ នឹងគ្រាប់អង្ករធម្មតា សំបកវេចខ្ចប់ កំណត់ពីកម្រិតវត្ថុធាតុមិនមែនផលិតផល និងលោហៈធ្ងន់ កាលបរិច្ឆេទផុតផលិតផល។ល។ | ត្រឹមចុងឆ្នាំ ២០២៥ |

## សូចនាករប្រតិបត្តិការគន្លឹះ ប្រយោល – លទ្ធផលចុងក្រោយដែលចង់សម្រេចបាន ឬអត្ថប្រយោជន៍ដែលគំនិតផ្តួចផ្តើមជាអាទិភាពត្រូវបានរៀបចំឡើង ដើម្បីសម្រេច

| សូចនាករប្រតិបត្តិការគន្លឹះ | សេចក្តីពិពណ៌នា | រយៈពេល |
|---|---|---|
| វិធានលិខិតបទដ្ឋានគតិយុត្តិស្តីពីអាហារូបត្ថម្ភត្រូវបានកែលម្អ | • វិធាន និងលិខិតបទដ្ឋានគតិយុត្តិ ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍ ការបញ្ចូលមីក្រូសារជាតិ និងការលក់ផលិតផលសម្បូរជីវជាតិ និងមានសុវត្ថិភាពត្រូវបានបញ្ជាក់យ៉ាងច្បាស់លាស់ និងផ្សព្វផ្សាយយ៉ាងមានប្រសិទ្ធភាព<br>• វិធាន និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការផ្សព្វផ្សាយទីផ្សារ ផ្សព្វផ្សាយពាណិជ្ជកម្ម និងដាក់លក់ផលិតផលសម្បូរជីវជាតិ បានទទួលការបញ្ជាក់យ៉ាងច្បាស់ និងត្រូវបានផ្សព្វផ្សាយយ៉ាងមានប្រសិទ្ធភាព | ត្រឹមចុងឆ្នាំ ២០២៥ |
| កិច្ចសន្ទនាជាប្រចាំ និងបើកចំហត្រូវបានធ្វើឡើងជាមួយនឹងរាជរដ្ឋាភិបាល | • មានការរៀបចំកិច្ចប្រជុំជាទៀងទាត់ ជាមួយនឹងស្ថាប័ន និងជនបង្គោលដែលទទួលបន្ទុកអាហារូបត្ថម្ភរបស់រាជរដ្ឋាភិបាល<br>• ការប្រឈម និងឱកាសពាក់ព័ន្ធនឹងអាហារូបត្ថម្ភរបស់វិស័យឯកជនត្រូវបានចែករំលែក និងផ្សព្វផ្សាយដោយចំហ ដើម្បីឆ្លុះបញ្ចាំងពីការយល់ឃើញរបស់វិស័យឯកជន<br>• SBN ត្រូវបានចាត់ទុកជាបណ្តាញដែលមានកេរ្តិ៍ឈ្មោះ និងអាចលើកឡើងពីការយល់ឃើញរបស់ខ្លួន ដែលជាបណ្តាញតំណាងឱ្យវិស័យឯកជនទាំងមូលដែលពាក់ព័ន្ធនឹងអាហារូបត្ថម្ភ និងជំរុញឱ្យមានការផ្តល់ការលើកទឹកចិត្តកាន់តែប្រសើរ ក្នុងទម្រង់ជាគោលនយោបាយសាធារណៈ ដើម្បីជំរុញការចូលរួមពី SME ក្នុងការលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ<br>• រាជរដ្ឋាភិបាលប្រើប្រាស់SBN ដើម្បីបញ្ចូលការយល់ឃើញ និងការបារម្ភរបស់វិស័យឯកជននៅដំណាក់កាលធ្វើផែនការនៅពេលដែលមានការផ្លាស់ប្តូរលិខិតបទដ្ឋានគតិយុត្តិនានា | ត្រឹមចុងឆ្នាំ ២០២៥ |
| ការបញ្ចូលមីក្រូសារជាតិត្រូវបានចាត់ទុកជាអាទិភាពឡើងវិញក្នុងរបៀបវារៈអាហារូបត្ថម្ភរបស់រាជរដ្ឋាភិបាល | • ប្រធានបទ ការបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារ ត្រូវបានចាត់ទុកថាជាគំនិតផ្តួចផ្តើម ជាយុទ្ធសាស្ត្រដ៏សំខាន់សម្រាប់អ្នកធ្វើសេចក្តីសម្រេចចិត្តអំពីអាហារូបត្ថម្ភរបស់រាជរដ្ឋាភិបាល | ត្រឹមចុងឆ្នាំ ២០២៥ |
| ការលើកកម្ពស់របបអាហារសុខភាពតាមរយៈ បទដ្ឋានគតិយុត្តិតាមរបៀបវារៈច្បាស់លាស់ | • រៀបចំកិច្ចសន្ទនារវាងរាជរដ្ឋាភិបាល និងវិស័យឯកជន អំពីការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តិ ដើម្បីជំរុញរបបអាហារទ្រទ្រង់សុខភាព និងកាត់បន្ថយការញ៉ាំអាហារ និងភេសជ្ជៈដែលប៉ះពាល់ដល់សុខភាព | ត្រឹមចុងឆ្នាំ ២០២៥ |

# សសរស្តម្ភជាយុទ្ធសាស្ត្រទី ៥ - គំនិតផ្តួចផ្តើម

## លើកកម្ពស់សុខភាព និងអាហារូបត្ថម្ភនៅតាមសហគមន៍ និងកន្លែងធ្វើការ

| របៀបអាន | ដឹកនាំ | គាំទ្រ | | | |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ៥ |

ការផ្តោតសំខាន់របស់យើងនៅទីនេះ: ដឹកនាំ / គាំទ្រ

"ក្រុមការងារ SBN សម្របសម្រួលគំនិតផ្តួចផ្តើមទាំងនេះ និងបានទទួលការគាំទ្រនៅកម្រិតផ្សេងៗ ពីអ្នកផ្តល់ជំនួយ ដៃគូ និងសមាជិក"

| គំនិតផ្តួចផ្តើម | សកម្មភាព | ដោយរបៀបណា | ផលជះ |
|---|---|---|---|
| ៥.១<br>គាំទ្រដល់គំនិតផ្តួចផ្តើមសុខភាព និងអាហារូបត្ថម្ភនៅកន្លែងធ្វើការ | ស្វែងរកការគាំទ្រ និងផ្តល់ការលើកទឹកចិត្ត ដល់ការអនុវត្តកម្មវិធីលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ នៅកន្លែងធ្វើការជាផ្នែកមួយនៃសកម្មភាពប្រចាំថ្ងៃរបស់ SBN កម្ពុជា | • សហការជាមួយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) សភាពាណិជ្ជកម្មកម្ពុជា សមាគមវាយនភ័ណ្ឌចិន រោងចក្រកាន់តែប្រសើរនៅកម្ពុជា ដើម្បីសម្របសម្រួលការអនុវត្តកម្មវិធីលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភនៅកន្លែងធ្វើការ ដល់ក្រុមហ៊ុនដែលមានសក្តានុពលនៅក្នុងឧស្សាហកម្មកាត់ដេរ ស្បែកជើង និងវាយនភ័ណ្ឌ<br>• ពង្រីកសកម្មភាពស្វែងរកការគាំទ្រដល់ការអនុវត្តកម្មវិធីលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ នៅកន្លែងធ្វើការជាមួយនឹងរោងចក្រផ្សេងទៀត និងជាមួយស្ថាប័នធំៗនៅក្នុងវិស័យដទៃទៀត<br>• ចែករំលែកព័ត៌មានជាមួយសមាជិក SBN អំពីអត្ថប្រយោជន៍ទទួលបានពីកម្មករនិយោជិតមានសុខភាពមាំមួន តាមរយៈព្រឹត្តិបត្រព័ត៌មាន និងក្រុម Facebook និងក្នុងអំឡុងកិច្ចប្រជុំជាទៀងទាត់ជាមួយនឹងតួអង្គពាក់ព័ន្ធវិស័យឯកជនក៏ដូចជាតាមរយៈព្រឹត្តិការណ៍នានា | M សមាជិក<br>L អ្នកប្រើប្រាស់<br>L ទីផ្សារ<br>M ស្ថានភាពអាហារូបត្ថម្ភ |
| ៥.២<br>ផ្តល់ ការបណ្តុះបណ្តាល ការណែនាំ ឧបករណ៍ និងព័ត៌មាន និងចែករំលែកការអនុវត្តល្អ ព្រមទាំងចំណេះដឹងនានា | កំណត់ និងអនុវត្តវិធីសាស្ត្រដែលមានប្រសិទ្ធភាព ដើម្បីផ្តល់ដំបូន្មាន ការណែនាំ ឬការបណ្តុះបណ្តាលតាមរយៈសិក្ខាសាលា ព្រឹត្តិការណ៍ ឧបករណ៍អនុវត្ត ការស្រាវជ្រាវ និងព័ត៌មាន ចែករំលែកឧបករណ៍ និងទម្រង់គំរូនានា ជាមួយនឹងសមាជិក | • តាមរយៈការសហការជាមួយនឹង ក.ក.ជ. និងប្រើប្រាស់ឧបករណ៍ និងការណែនាំដែលរៀបចំដោយSBN ដទៃទៀត រៀបចំការបណ្តុះបណ្តាល និងផលិតឧបករណ៍ស្វែងរកមតិគាំទ្រ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីអនុវត្តម៉ូឌុលចំនួន ៤ នៃកម្មវិធីលើកកម្ពស់អាហារូបត្ថម្ភ នៅកន្លែងធ្វើការ (អាហារទ្រទ្រង់សុខភាពនៅកន្លែងធ្វើការ ការអប់រំអំពីអាហារូបត្ថម្ភ ការត្រួតពិនិត្យសុខភាព និងគាំទ្រដល់ការបំបៅកូនដោយទឹកដោះ)<br>• សាកល្បងកម្មវិធីនេះជាមួយនឹងសមាជិកមួយចំនួនរបស់ SBN<br>• គាំទ្រដល់ការពង្រីកយុទ្ធនាការនេះនៅទូទាំងប្រទេស ក្នុងទម្រង់ជាសិក្ខាសាលាបណ្តុះបណ្តាលគ្រូបង្គោល (ToT) ដល់មណ្ឌលសុខភាពថ្នាក់ស្រុក និងសមាជិក SBN នៅក្នុងវិស័យកាត់ដេរ និងរោងចក្រនានា<br>• ចែករំលែកចំណេះដឹង ជំនាញឯកទេស និងបទពិសោធន៍ដែលទទួលបានជាមួយនឹង SBN ដទៃទៀតនៅអាស៊ី | M សមាជិក<br>L អ្នកប្រើប្រាស់<br>L ទីផ្សារ<br>M ស្ថានភាពអាហារូបត្ថម្ភ |

| គំនិតផ្តួចផ្តើម | សកម្មភាព | ដោយរបៀបណា | ផលជះ |
|---|---|---|---|
| ៥.៣<br>បង្កើនការផ្គត់ផ្គង់ផលិតផលនិងការរកដំណោះស្រាយ ដើម្បីលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភនៅតាមសហគមន៍ | ផ្សព្វផ្សាយផលិតផលពាក់ព័ន្ធនឹងទឹកស្អាត និងអនាម័យ និងដំណោះស្រាយក្នុងខ្សែច្រវាក់អាហារ និងការអនុវត្តដំណោះស្រាយទាំងនេះ ជាពិសេសនៅតាមសហគមន៍ជនបទ និងងាយរងគ្រោះ | • តាមរយៈការសហការជាមួយនឹងទីភ្នាក់ងារសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍ដទៃទៀត កំណត់ពីវិស័យឯកជនដែលផ្តល់នូវផលិតផល និងដំណោះស្រាយសម្រាប់ដោះស្រាយបញ្ហាអនាម័យ ការលាងសម្អាតដៃ និងទឹកសម្រាប់ផឹក<br>• ផ្តល់ការកសាងសមត្ថភាព តភ្ជាប់ទំនាក់ទំនងទីផ្សារជាមួយនឹងក្រុមហ៊ុនខាងលើ<br>• រៀបចំឱ្យមានដំណោះស្រាយខ្សែច្រវាក់អាហារដែលសមស្របសម្រាប់ផលិតផលកសិផល អាហារទ្រទ្រង់សុខភាព និងអង្ករដែលបញ្ចូលមីក្រូសារជាតិ | M សមាជិក<br>H អ្នកប្រើប្រាស់<br>L ទីផ្សារ<br>M ស្ថានភាពអាហារូបត្ថម្ភ |
| ៥.៤<br>លើកទឹកចិត្តឱ្យមានការគាំទ្រដល់អាហារូបត្ថម្ភតាមរយៈកម្មវិធី CSR | លើកទឹកចិត្ត និងការចូលរួមក្នុងកម្មវិធីអាហារូបត្ថម្ភ តាមរយៈកម្មវិធី CSR សម្រាប់សមាជិក SBN ដែលមានស្រាប់ និងសមាជិកសក្តានុពល | • ជួបប្រជុំជាប្រចាំជាមួយនឹងសម្ព័ន្ធសង្គមស៊ីវិលនៃចលនាបង្កើនអាហារូបត្ថម្ភ ដើម្បីកំណត់ពីឱកាសរៀបចំគំនិតផ្តួចផ្តើម CSR ផ្តោតលើអាហារូបត្ថម្ភ<br>• ផ្សព្វផ្សាយពីគំនិតផ្តួចផ្តើមអាហារូបត្ថម្ភនៃកម្មវិធី CSR ដល់ក្រុមហ៊ុនដែលធ្វើការងារមិនពាក់ព័ន្ធអាហារ ហើយដែលមានថវិកាច្រើនសម្រាប់អនុវត្តកម្មវិធី CSR ចែករំលែកករណីសិក្សាដែលបង្ហាញពីជោគជ័យ<br>• ចែករំលែកឱកាសអំពីការចូលរួមរបស់កម្មវិធី CSR ក្នុងការដោះស្រាយបញ្ហាអាហារូបត្ថម្ភដល់សមាជិក SBN បច្ចុប្បន្ន និងសមាជិកសក្តានុពល ផ្សារភ្ជាប់ទំនាក់ទំនងរវាងសមាជិក SBN ជាមួយនឹងឱកាសនានា | L សមាជិក<br>L អ្នកប្រើប្រាស់<br>L ទីផ្សារ<br>M ស្ថានភាពអាហារូបត្ថម្ភ |

# សសរស្តម្ភជាយុទ្ធសាស្ត្រទី ៥ -សូចនាករប្រតិបត្តិការគន្លឹះ

## លើកកម្ពស់សុខភាព និងអាហារូបត្ថម្ភនៅតាមសហគមន៍ និងកន្លែងធ្វើការ

| របៀបអាន | ដឹកនាំ | គាំទ្រ | | | |
|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ៥ |

| ការផ្តោតសំខាន់របស់យើងនៅទីនេះ | ដឹកនាំ / គាំទ្រ | "ក្រុមការងារ SBN សម្របសម្រួលគំនិតផ្តួចផ្តើមទាំងនេះ និងបានទទួលការគាំទ្រនៅកម្រិតផ្សេងៗ ពីអ្នកផ្តល់ជំនួយ ដៃគូ និងសមាជិក" |
|---|---|---|

### សូចនាករប្រតិបត្តិការគន្លឹះ ផ្ទាល់ – រង្វាស់ភាពជោគជ័យសម្រាប់ SBN

| សូចនាករប្រតិបត្តិការគន្លឹះ | សេចក្តីពិពណ៌នា | រយៈពេល |
|---|---|---|
| យ៉ាងតិចក្រុមហ៊ុន ១0 អនុវត្តកម្មវិធីសុខភាព នឹងអាហារូបត្ថម្ភនៅកន្លែងធ្វើការ | • ត្រូវមានក្រុមហ៊ុនយ៉ាងតិចណាស់ចំនួន ១0 អនុវត្តគំនិតផ្តួចផ្តើម លើកកម្ពស់សុខភាព និងអាហារូបត្ថម្ភនៅកន្លែងធ្វើការប្រកបដោយជោគជ័យ (ឧទាហរណ៍ បានរៀបចំសិក្ខាសាលាស្តីពីអាហារូបត្ថម្ភ បានបង្កើតកម្មវិធីសុខភាពស្តីពីអាហារូបត្ថម្ភ  សម្រាប់បុគ្គលិកអនុវត្តគំនិតផ្តួចផ្តើមអាហារទ្រទ្រង់សុខភាពដោយផ្ទាល់ ដូចជាក្រុមហ៊ុនឧបត្ថម្ភចានដាក់ផ្លែឈើ ផ្តល់ការគាំទ្រដល់ការបំបៅកូនដោយទឹកដោះជាដើម ។ល។) | ត្រឹមចុងឆ្នាំ ២០២៥ |
| ឯកសារណែនាំ/ឧបករណ៍ស្តីពីការលើកកម្ពស់ អាហារូបត្ថម្ភនៅកន្លែងធ្វើការយ៉ាងតិច ១ ត្រូវបានរៀបចំឡើង | • មានសៀវភៅណែនាំ/ឧបករណ៍ស្តីពីអាហារូបត្ថម្ភនៅកន្លែងធ្វើការយ៉ាងតិចណាស់ ១ ត្រូវបានរៀបចំ និងសម្រិតសម្រាំង ឱ្យស្របតាមបរិបទក្នុងប្រទេសកម្ពុជា តាមរយៈការសហការជាមួយនឹង ក.ក.ជ. | ត្រឹមចុងឆ្នាំ ២០២២ |
| ការតភ្ជាប់ទំនាក់ទំនងយ៉ាងតិច ៥ ត្រូវបានធ្វើឡើងសម្រាប់ផលិតផល នឹងដំណោះស្រាយទាំងឡាយ ដើម្បីរួមចំណែកដល់ការលើកកម្ពស់អាហារូបត្ថម្ភ | • កំណត់ពីផលិតផល និងដំណោះស្រាយបង្កើនអនាម័យ ទឹកស្អាត និងអាហារូបត្ថម្ភដទៃទៀត ដែលអាចផ្តល់ដល់វិស័យឯកជន និងជួយនាំយកផលិតផល និងដំណោះស្រាយទាំងនោះ មកកាន់ទីផ្សារតាមរយៈការផ្តល់ការកសាងសមត្ថភាពដល់អ្នកផលិត និងការផ្សារភ្ជាប់ទំនាក់ទំនងទីផ្សារ ជាមួយនឹងអ្នកប្រើប្រាស់/អ្នកទិញផលិតផលទាំងនោះ | ត្រឹមចុងឆ្នាំ ២០២៥ |
| សមាជិក SBN យ៉ាងតិច  ៥ បានចូលរួមនៅក្នុងគំនិតផ្តួចផ្តើមអាហារូបត្ថម្ភតាមរយៈកម្មវិធី CSR | • កំណត់យកក្រុមហ៊ុនធំៗយ៉ាងតិចណាស់ចំនួន ៥ ដែលមានសក្តានុពលចូលរួមកម្មវិធីលើកកម្ពស់អាហារូបត្ថម្ភតាមរយៈការអនុវត្តកម្មវិធី CSR<br>• ទាក់ទងទៅកាន់ក្រុមហ៊ុនទាំងនេះ និងផ្តល់ព័ត៌មានសាវតារអំពីSBN និងទិដ្ឋភាពរួមទូទៅអំពីស្ថានភាពអាហារូបត្ថម្ភនៅកម្ពុជា ប្រយោជន៍ដែលបានពីការលើកកម្ពស់អាហារូបត្ថម្ភ និងសង្ខេបពីឱកាសឬវិស័យដែលមានស្រាប់សម្រាប់ចូលរួមសហការ<br>• ចុះឈ្មោះក្រុមហ៊ុនទាំងនេះជាផ្លូវការក្នុងSBN កម្ពុជា | ត្រឹមចុងឆ្នាំ ២០២៥ (១ per year) |

**សូចនាករប្រតិបត្តិការគន្លឹះ ប្រយោល – លទ្ធផលចុងក្រោយដែលចង់សម្រេចបាន ឬអត្ថប្រយោជន៍ដែលគំនិតផ្តួចផ្តើមជាអាទិភាពត្រូវបានរៀបចំឡើង ដើម្បីសម្រេច**

| សូចនាករប្រតិបត្តិការគន្លឹះ | សេចក្តីពិពណ៌នា | រយៈពេល |
|---|---|---|
| ការផ្សព្វផ្សាយ និងការផ្តល់លទ្ធភាពឱ្យកម្មករនិយោជិតអាចទទួលបានផលិតផលដែលសម្បូរជីវជាតិ ព្រមទាំងសេវាសុខភាព និងអាហារូបត្ថម្ភនៅកន្លែងធ្វើការរបស់ពួកគេកើនឡើង | ជម្រើសអាហារ និងភេសជ្ជៈ សម្បូរដោយសារធាតុចិញ្ចឹមមានកាន់តែច្រើនសម្រាប់កម្មករនិយោជិតនៅក្នុងក្រុមហ៊ុន ក៏ដូចជាសេវាសុខភាព និងអាហារូបត្ថម្ភ (សិក្ខាសាលាស្តីពីអាហារូបត្ថម្ភ និងសុខភាពសម្រាប់កន្លែងធ្វើការ ការបង្រៀនអំពីរបៀបចម្អិនអាហារ សិក្ខាសាលាអាហារូបត្ថម្ភ ការពិនិត្យសុខភាព និងការគាំទ្រដល់ការបំបៅកូនដោយទឹកដោះ ។ល។) | ត្រឹមចុងឆ្នាំ ២០២៥ |
| លើកកម្ពស់ស្ថានភាពទឹកស្អាត និងអនាម័យនៅតាមសហគមន៍ | កម្មវិធីអនាម័យជាមូលដ្ឋាន ត្រូវបានរៀបចំឡើងនៅតាមផ្ទះ សាលារៀន និងមណ្ឌលសុខភាព ដែលទទួលបានការគាំទ្រតាមរយៈការអប់រំ អំពីសារៈសំខាន់នៃការអនុវត្តទឹកស្អាត និងអាហារដែលមានអនាម័យ ឱ្យបានត្រឹមត្រូវ | ត្រឹមចុងឆ្នាំ ២០២៥ |
| លទ្ធភាពទទួលបានអាហារដែលមានសុវត្ថិភាព សម្បូរជីវជាតិ និងមានតម្លៃសមរម្យកើនឡើង | កែលម្អខ្សែច្រវាក់ផ្គត់ផ្គង់ ដើម្បីបង្កើនភាពអាចរកបាននៃអាហារ និងអង្ករបញ្ចូលមីក្រូសារជាតិ ដើម្បីសុវត្ថិភាព សម្បូរជីវជាតិ និងមានតម្លៃសមរម្យ | ត្រឹមចុងឆ្នាំ ២០២៥ |




Stainless steel
Dehydrator
ON
TIME
90℃
80℃
70℃
ITEM
HERBS
RAISING BREAD
YOGURT
VEGETABLES
FRUIT&FRUIT ROLLS
MEATS,FISH&JERKY




# ៤ អភិបាលកិច្ច

## អ្នកដែលចូលរួម ដើម្បីឱ្យសកម្មភាពនានាអាចកើតឡើងបាន

# រចនាសម្ព័ន្ធ SBN កម្ពុជា

**ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (ក.ក.ជ.)**

**WFP World Food Programme** – កម្មវិធីស្បៀងអាហារពិភពលោក

**គណៈកម្មាធិការដឹកនាំ (WFP និង ក.ក.ជ)**
- គណនេយ្យភាព និងត្រួតពិនិត្យ
- ផ្តល់ការណែនាំសម្រាប់ការសម្រេចចិត្តធំៗ
- កិច្ចប្រជុំប្រចាំឆមាស

**Scaling Up NUTRITION – Business Network – ENGAGE • INSPIRE • INVEST**
បណ្តាញធុរកិច្ចនៃចលនាបង្កើនអាហារូបត្ថម្ភ កម្ពុជា

**ក្រុមប្រឹក្សាផ្តល់យោបល់**
- វិស័យឯកជន ៥០%+
- ផ្តល់ការណែនាំកម្រិតយុទ្ធសាស្ត្រដល់SBN
- កិច្ចប្រជុំប្រចាំឆមាស

ដឹកនាំ និងគាំទ្រ

**សមាជិកនៃបណ្តាញធុរកិច្ច នៃចលនាបង្កើនអាហារូបត្ថម្ភ**

- ផលិតកម្ម និង ការកែច្នៃស្បៀង
- កសិកម្ម
- លក់រាយ
- ហិរញ្ញវត្ថុ
- ដឹកជញ្ជូន និងចែកចាយ
- សំណង់
- សេវាវិជ្ជាជីវៈ
- បណ្តាញទូរស័ព្ទចល័ត និងគមនាគមន៍
- ថាមពល សេវាសាធារណៈ និងរ៉ែ
- រាជរដ្ឋាភិបាល
- UN
- អ្នកផ្តល់ជំនួយ
- អង្គការសង្គមស៊ីវិល
- សមាគមធុរកិច្ច
- ការស្រាវជ្រាវ និងការអប់រំ
- ការថែទាំសុខភាព
- សហគមន៍អាហារូបត្ថម្ភ

សហគមន៍អ្នកអនុវត្តការងារតាមវិស័យ | សហគមន៍អ្នកអនុវត្តការងារតាមវិស័យ | សហគមន៍អ្នកអនុវត្តការងារតាមវិស័យ

# តួនាទី និងភារកិច្ច

ផ្អែកតាមរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ក្រុមនីមួយៗ ត្រូវបានបង្ហាញដូចខាងក្រោម

| | បុគ្គល/ ភាគីសំខាន់ៗ | តួនាទី | RACI | រចនាសម្ព័ន្ធត្រួតពិនិត្យ និងរាយការណ៍ |
|---|---|---|---|---|
| | តើនរណាខ្លះដែលជាសមាសភាព នៅក្នុងក្រុមនេះ | តើពួកគេមានតួនាទីអ្វីខ្លះនៅក្នុងចលនា SBN កម្ពុជា | តើពួកគេមានការទទួលខុសត្រូវកម្រិតណា ចំពោះវឌ្ឍនភាពនៃចលនានៅកម្ពុជា? | តើពួកគេរាយការណ៍ទៅនរណា និងត្រួតពិនិត្យលើអ្វីខ្លះ? |
| ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍ វិស័យកសិកម្ម និងជនបទ (ក.ក.ជ) | • អគ្គលេខាធិការ ក.ក.ជ. និងអ្នកសម្របសម្រួលចលនាបង្កើនអាហារូបត្ថម្ភកម្ពុជា | ស្ថាប័នរាជរដ្ឋាភិបាលដឹកនាំកិច្ចខិតខំប្រឹងប្រែង នៃចលនាបង្កើនអាហារូបត្ថម្ភនៅកម្ពុជា។ ធ្វើប្រតិភូកម្មតួនាទីសម្របសម្រួលទៅឱ្យ WFP និងក្រុម ការងារ SBN | C (ផ្តល់ព័ត៌មានជូនជ្រាប) បន្តទទួលបាន បច្ចុប្បន្នភាពអំពីវឌ្ឍនភាព មានការផ្តល់ធាតុចូលតាមរយៈកិច្ចប្រជុំរបស់គណៈកម្មាធិការដឹកនាំ | ត្រួតពិនិត្យសកម្មភាពនៃគំនិតផ្តួចផ្តើមទាំងអស់ របស់ចលនាបង្កើនអាហារូបត្ថម្ភ នៅកម្ពុជា។ ធ្វើប្រតិភូកម្ម ការសម្រប សម្រួល SBN ទៅឱ្យ WFP |
| គណៈកម្មាធិការដឹកនាំ | • អគ្គលេខាធិការ ក.ក.ជ<br>• តំណាង និងនាយកប្រចាំប្រទេស WFP កម្ពុជា | ជួបប្រជុំប្រចាំឆមាស ដើម្បីវាយតម្លៃវឌ្ឍនភាព។ ធ្វើការត្រួតពិនិត្យ និងគណនេយ្យភាព | A (គណនេយ្យភាព) មានគណនេយ្យភាពចំពោះវឌ្ឍនភាពរបស់បណ្តាញ | ត្រួតពិនិត្យសកម្មភាពនៃបណ្តាញធុរកិច្ច នៅកម្ពុជានៃចលនា បង្កើនអាហារូបត្ថម្ភ។ ធ្វើប្រតិភូកម្ម ការអនុវត្ត SBN ទៅឱ្យ ក្រុមការងារ SBN |
| ក្រុមប្រឹក្សាផ្តល់យោបល់ សម្រាប់ចលនាSBN នៅកម្ពុជា* | • សមាជិកមិនទាន់បានបញ្ជាក់នៅឡើយ (គិតត្រឹមខែមិថុនា ឆ្នាំ ២០២១)។ ប្រធានពី ក.ក.ជ. និង សហប្រធានពីវិស័យឯកជន និងត្រូវបោះឆ្នោតជ្រើសរើសដោយសមាជិកនៃក្រុមប្រឹក្សាផ្តល់យោបល់ | ជួបប្រជុំប្រចាំឆមាស ដើម្បីផ្តល់ការណែនាំ កម្រិតយុទ្ធសាស្ត្រ និងធាតុចូល | C (ពិគ្រោះយោបល់ជាមួយ) នឹងផ្លាស់ទៅរកគណនេយ្យភាពវិញនៅឆ្នាំខាងមុខ | ពុំមានឋានានុក្រមរាយការណ៍ជាផ្លូវការនោះឡើយ ឋានានុក្រមទាំងនេះនឹងត្រូវកំណត់នៅពេលដែលក្រុមប្រឹក្សាផ្តល់យោបល់ទទួលយកគណនេយ្យភាពបន្ថែមទៀត |

| | បុគ្គល/ ភាគីសំខាន់ៗ | តួនាទី | RACI | រចនាសម្ព័ន្ធត្រួតពិនិត្យ និងរាយការណ៍ |
|---|---|---|---|---|
| | តើនរណាខ្លះដែលជាសមាសភាព នៅក្នុងក្រុមនេះ | តើពួកគេមានតួនាទីអ្វីខ្លះនៅក្នុងចលនា SBN កម្ពុជា | តើពួកគេមានការទទួលខុសត្រូវកម្រិតណា ចំពោះវឌ្ឍនភាពនៃចលនានៅកម្ពុជា? | តើពួកគេរាយការណ៍ទៅនរណា និងត្រួតពិនិត្យលើអ្វីខ្លះ? |
| ក្រុមការងារ SBN នៅកម្ពុជា (នៅក្នុង WFP កម្ពុជា) | • អ្នកសម្របសម្រួល SBN កម្ពុជា<br>• ជំនួយការរដ្ឋបាល<br>• បុគ្គលិកដែលផ្ទេរពីផ្នែកផ្សេងទៀត អ្នកស្ម័គ្រចិត្ត និងតួនាទីគាំទ្រដទៃទៀត | សម្របសម្រួលសកម្មភាពរបស់បណ្ដាញ ប្រចាំថ្ងៃ | R (ទទួលខុសត្រូវ) | រាយការណ៍ផ្ទាល់ទៅកាន់គណៈកម្មាធិការដឹកនាំ |
| សហអ្នកសម្របសម្រួល SBN នៅកម្រិតសកល | • កម្មវិធីស្បៀងអាហារពិភពលោក (WFP) និងសម្ព័ន្ធសកលសម្រាប់លើកកម្ពស់អាហារូបត្ថម្ភ (GAIN) | ផ្ដល់ការគាំទ្រកម្រិតខ្ពស់ ជាផ្នែកមួយ នៃចលនាបង្កើនអាហារូបត្ថម្ភ ទូទៅ | I (ផ្ដល់ព័ត៌មានជូនជ្រាប) | WFP និង GAIN ត្រូវបានតំណាង នៅក្នុងក្រុមប្រឹក្សាផ្ដល់យោបល់នៃSBN ជាសកល នាយកប្រតិបត្តិ WFP និង នាយកប្រតិបត្តិ GAIN |
| ក្រុមប្រឹក្សាផ្ដល់យោបល់ និងក្រុមការងារនៃចលនា SBN សកល | • ក្រុមប្រឹក្សាផ្ដល់យោបល់មានសមាសភាពជាថ្នាក់ដឹកនាំជាន់ខ្ពស់ជាច្រើនមកពីវិស័យឯកជន និង នាយក ប្រតិបត្តិនៃ WFP និង GAIN<br>• ប្រធានដឹកនាំក្រុមការងារសកល ដែលមានមូលដ្ឋាននៅក្នុងអង្គការ GAIN ទីក្រុង ឡុង | ដាក់ចេញនូវទិសដៅជាយុទ្ធសាស្ត្រសម្រាប់បណ្ដាញនៅថ្នាក់សកល និង សម្របសម្រួល កិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសជាសមាជិក | C (ពិគ្រោះយោបល់ជាមួយ)។ មានការសុំយោបល់ និង ការណែនាំពីក្រុមការងារនៅកម្រិតសកលជាទៀងទាត់ | ក្រុមការងារSBN សកល រាយការណ៍ផ្ទាល់ ទៅកាន់ក្រុមប្រឹក្សាផ្ដល់យោបល់ និង តួអង្គពាក់ព័ន្ធនៅក្នុង GAIN និង WFP |

* នៅពេលដែលចលនា SBN នៅកម្ពុជាមានភាពចាស់ទុំ នៅពេលដែលវិស័យឯកជនទទួលយកការទទួលខុសត្រូវបន្ថែមទៀត ក្នុងការដឹកនាំគំនិតផ្ដួចផ្ដើម SBN នឹងមានការកែសម្រួលក្របខ័ណ្ឌខាងលើនៅពេលដែលតួនាទី និងការទទួលខុសត្រូវមានការផ្លាស់ប្ដូរ។

* RACI (R: ទទួលខុសត្រូវ; A: គណនេយ្យភាព; C: ពិគ្រោះយោបល់ជាមួយ; I: ផ្ដល់ព័ត៌មានជូនជ្រាប)





៥ សមាជិកភាព

មូលដ្ឋានសម្រាប់បណ្តាញធុរកិច្ចនៃចលនា បង្កើនអាហារូបត្ថម្ភ

# សមាជិកគោលដៅនៃបណ្តាញធុរកិច្ចនៃចលនា បង្កើនអាហារូបត្ថម្ភ

## ទិដ្ឋភាពរួមទូទៅនៃក្របខ័ណ្ឌសមាជិកភាព

- ដូចរៀបរាប់នៅក្នុងផ្នែក 'យុទ្ធសាស្ត្រសង្ខេប' គំនិតផ្តួចផ្តើមជាអាទិភាពរបស់ SBN គឺ 'ជ្រើសរើស និងរក្សាទុកសមាជិកដែលមានកេរ្តិ៍ឈ្មោះ និងការប្តេជ្ញាចិត្តខ្ពស់'
- ខាងក្រោមនេះគឺជាការបង្ហាញជារួមពីក្រុមផ្សេងៗ ដែលSBN មានបំណងចង់កៀរគរឱ្យមកធ្វើជាសមាជិក
- SBN មានគោលបំណងចុះឈ្មោះជាផ្លូវការសមាជិកយ៉ាងតិចណាស់ ៥០ គិតត្រឹមចុងឆ្នាំ ២០១៥

| ក្រុមឧស្សាហកម្ម | សនិទានភាពសម្រាប់ធ្វើជាសមាជិកនៃ |
|---|---|
| ផលិតកម្ម និងការកែច្នៃស្បៀង | • ធ្វើការរួមគ្នា ដើម្បីបង្កើនការយល់ដឹង និងបង្កើនតម្រូវការទីផ្សារ សម្រាប់ផលិតផលអាហារ និងភេជ្ជៈដែលសម្បូរជីវជាតិ<br>• ជំរុញឱ្យមានការកែលម្អបរិយាកាសគតិយុត្តិ ដើម្បីសម្រួលដល់ការធ្វើអាជីវកម្មក្នុងវិស័យស្បៀង និងអាហារូបត្ថម្ភ<br>• ទទួលបាន ការបណ្តុះបណ្តាល ឧបករណ៍ និងទម្រង់គំរូ ដើម្បីកសាងយុទ្ធសាស្ត្រអាជីវកម្មឱ្យបានរឹងមាំជុំវិញបញ្ហាអាហារូបត្ថម្ភ<br>• ពង្រីកមូលដ្ឋានអតិថិជន និងបង្កើនការយល់ដឹងអំពីទីផ្សារ និងអ្នកប្រើប្រាស់ |
| កសិកម្ម | • ជួយធ្វើឱ្យទីផ្សារផលិតផលអាហារចម្រុះឱ្យមានការរីកចម្រើន<br>• គាំទ្រដល់កសិករកម្ពុជាក្នុងការលើកកម្ពស់ផលិតផលស្បៀងដែលផលិតនៅក្នុងស្រុក និងផលិតផលស្បៀងរបស់ជនជាតិដើមភាគតិច |
| លក់រាយ ភោជនីយដ្ឋាន | • ចងក្រងបណ្តាញជាមួយនឹងស្ថាប័ននានានៅក្នុងខ្សែច្រវាក់តម្លៃអាហារ<br>• ស្វែងយល់ពីផលិតផលអាហារនិងភេជ្ជៈថ្មីៗ ជំរុញឱ្យមានការពង្រីកទីផ្សារផលិតផលអាហារដែលសម្បូរជីវជាតិ បង្កើនការយល់ដឹងអំពីរបបអាហារសុខភាព និងអាហារដែលសម្បូរជីវជាតិ<br>• ចាប់ផ្តើមប្រើប្រាស់របៀបចម្អិនអាហារបែបថ្មី ដែលទ្រទ្រង់សុខភាពនិងផ្តល់នូវអាហារូបត្ថម្ភ ចាប់ផ្តើមលក់អាហារដែលមានប្រភពពីរុក្ខជាតិ |
| ហិរញ្ញវត្ថុ | ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ៖<br>• ផ្សព្វផ្សាយពីឱកាសវិនិយោគ និងផ្តល់ហិរញ្ញប្បទានដែលមានសក្តានុពលសម្រាប់ឧស្សាហកម្មអាហារ និងអាហារូបត្ថម្ភ<br>• ជំរុញកំណើនអាហារូបត្ថម្ភតាមរយៈការផ្តល់ហិរញ្ញប្បទានដល់គំនិតផ្តួចផ្តើមអាហារូបត្ថម្ភ ដែលផ្តល់នូវប្រាក់ចំណេញខ្ពស់ និងមានផលជះខ្ពស់នៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់អាហារ |

| ក្រុមឧស្សាហកម្ម | សនិទានភាពសម្រាប់ធ្វើជាសមាជិកនៃSBN |
|---|---|
| ដឹកជញ្ជូន និងចែកចាយ | • ឱកាសចងក្រងបណ្តាញជាមួយនឹងស្ថាប័ននានា ដែលមានបំណងចង់ពង្រីកខ្សែច្រវាក់ផ្គត់ផ្គង់របស់ខ្លួននៅកម្ពុជា<br>• ធ្វើការរួមគ្នា ដើម្បីបង្កើតភាពជាដៃគូសម្រាប់ធ្វើការចែកចាយ និងទាញប្រយោជន៍ពីបណ្តាញដែលមានស្រាប់ ដើម្បីបង្កើនប្រសិទ្ធភាពនៃការចែកចាយ<br>• ជួយធ្វើឱ្យអាហារដែលសម្បូរជីវជាតិងាយស្រួលទទួលបាន និងមានតម្លៃសមរម្យសម្រាប់អតិថិជនតាមរយៈការជួយកាត់បន្ថយថ្លៃដើមក្នុងការចែកចាយ |
| សេវាវិជ្ជាជីវៈ<br>រោងចក្រ<br>វាយនភ័ណ្ឌ កាត់ដេរ<br>ថាមពល សេវាសាធារណៈ និងរ៉ែ សំណង់<br>បណ្តាញទូរស័ព្ទចល័ត និងគមនាគមន៍ | • បង្កើតគំនិតផ្តួចផ្តើមលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ ក្នុងចំណោមកម្មករនិយោជិត គំនិតផ្តួចផ្តើម ទាំងនេះអាចជួយបង្កើនផលិតភាពបុគ្គលិក កាត់បន្ថយបន្ទុកនៃការសុំច្បាប់សម្រាកឈឺ និងលើកទឹកចិត្តឱ្យមានការលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភនៅតាមគ្រួសារ និងសហគមន៍របស់កម្មករនិយោជិត<br>• ស្វែងយល់ពីឱកាស CSR ដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហាអាហារូបត្ថម្ភ<br>• ផ្តល់សេវាដល់សមាជិក SBN (ឧទាហរណ៍ សេវាផ្តល់លិខិតបញ្ជាក់ ជំនួយបច្ចេកទេស)<br>• កសាងការយល់ដឹងដល់អ្នកប្រើប្រាស់ និងតម្រូវផលិតផលអាហារូបត្ថម្ភឱ្យកាន់តែប្រសើរ |
| រាជរដ្ឋាភិបាល | • ចូលរួម និងផ្តល់ការគាំទ្រដល់កិច្ចសន្ទនា ដើម្បីបង្កើនការចូលរួមរបស់វិស័យឯកជននៅក្នុងវិស័យអាហារូបត្ថម្ភ<br>• ស្តាប់សម្លេងរួមរបស់វិស័យឯកជន និងស្វែងយល់ពីបញ្ហា និងឱកាសនានា ដើម្បីធ្វើឱ្យបរិយាកាស គោលនយោបាយ និងគតិយុត្តិកាន់តែមានភាពល្អប្រសើរ |
| អង្គការសហប្រជាជាតិ | • បន្តទទួលបានព័ត៌មានបច្ចុប្បន្នភាពពីនិន្នាការ ការអភិវឌ្ឍ និងការស្រាវជ្រាវចុងក្រោយផ្តោតលើ អាហារូបត្ថម្ភនៅក្នុងវិស័យឯកជន<br>• ធានាឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីចូលរួម សហការជាមួយនឹងវិស័យឯកជន ដើម្បីលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ |
| អ្នកផ្តល់ជំនួយ | • ទទួលបានព័ត៌មានបច្ចុប្បន្នភាពជាទៀងទាត់ និងចងក្រងបណ្តាញ ដើម្បីបង្ហាញពីឱកាសទទួលបានថវិកាគាំទ្រសម្រាប់វិស័យឯកជនដែលធ្វើការងារពាក់ព័ន្ធនឹងអាហារូបត្ថម្ភ<br>• បន្តរក្សាបច្ចុប្បន្នភាពតាមរយៈការទទួលដំណឹងព័ត៌មានចុងក្រោយពាក់ព័ន្ធនឹងការចូលរួមរបស់វិស័យឯកជន ក្នុងការលើកម្ពស់ស្ថានភាពអាហារូបត្ថម្ភ |
| អង្គការសង្គមស៊ីវិល | • ចងក្រងបណ្តាញជាមួយនឹងដៃគូវិស័យឯកជនដែលមានសក្តានុពល ដើម្បីទទួលបានការគាំទ្របច្ចេកទេស សម្រាប់គំនិតផ្តួចផ្តើមអាហារូបត្ថម្ភដែលមានលក្ខណៈពាណិជ្ជកម្ម<br>• ស្វែងយល់ពីគំនិតផ្តួចផ្តើមអាហារូបត្ថម្ភជាលក្ខណៈពាណិជ្ជកម្ម ដែលជាការអនុវត្តល្អ និងនិន្នាការនានា ដែលអាចយកមកអនុវត្តក្នុងបរិបទអង្គការសង្គមស៊ីវិល |
| ការស្រាវជ្រាវ និងការអប់រំ | • ផ្តល់ធាតុចូល និងមតិត្រឡប់ផ្នែកតាមការស្រាវជ្រាវ និងការធ្វើពិសោធន៍អាហារូបត្ថម្ភថ្មីៗក្នុងស្រុក និងនៅអន្តរជាតិ<br>• ផ្តល់ឱកាសអាជីព និងឱកាសសម្រាប់បណ្តុះបណ្តាលសិស្ស និស្សិត និងនិស្សិតដែលបញ្ចប់ការសិក្សាផ្នែកអាហារូបត្ថម្ភ |
| ការថែទាំសុខភាព<br>សមាគមធុរកិច្ច<br>សហគមន៍អាហារូបត្ថម្ភ | • ស្វែងរកព័ត៌មានអំពីនិន្នាការទីផ្សារចុងក្រោយ និងផលិតផលអាហារូបត្ថម្ភ ដែលអាចយកមកចែករំលែកជាមួយនឹងអតិថិជន និងអ្នកពាក់ព័ន្ធ<br>• ចូលរួមនៅក្នុងកិច្ចសន្ទនាទូទៅ ស្តីពីការលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ និងជួយបង្កើនតម្រូវការអាហារដែលសម្បូរជីវជាតិក្នុងចំណោមអ្នកប្រើប្រាស់<br>• ចងក្រងបណ្តាញជាមួយនឹងស្ថាប័នដទៃទៀត ដែលមានគោលដៅរួមនៅក្នុងខ្សែច្រវាក់តម្លៃអាហារ |

## ក្នុងនាមជាសមាជិករបស់SBN

### អត្ថប្រយោជន៍នៃការក្លាយជាសមាជិកនៃSBN កម្ពុជា

- ចងក្រងបណ្តាញជាមួយនឹងក្រុមហ៊ុនដទៃទៀត (ក្នុងស្រុក និងកម្រិតសកល) អង្គការសង្គមស៊ីវិល ទីភ្នាក់ងារសហប្រជាជាតិ អ្នកផ្តល់ជំនួយ ដែលមានចំណាប់អារម្មចំពោះវិស័យអាហារូបត្ថម្ភ និងការពង្រីកទីផ្សារអាហារូបត្ថម្ភ
- រួមចំណែកដល់ការលើកជាសម្លេងនិងជាសហគមន៍តែមួយ សម្រាប់អាហារូបត្ថម្ភនៅក្នុងវិស័យឯកជននៅកម្ពុជា
- រៀនសូត្រពីគ្នា និងចែករំលែកការអនុវត្តល្អៗពាក់ព័ន្ធនឹងការវិនិយោគលើអាហារូបត្ថម្ភ
- ស្វែងយល់ពីឱកាសកសាងភាពជាដៃគូសហការជាមួយគ្នា ក៏ដូចជាសហការជាមួយនឹងអង្គការក្រៅរដ្ឋាភិបាល សមាគមវិជ្ជាជីវៈ ព្រមទាំងអង្គការស្ថាប័នពាក់ព័ន្ធដទៃទៀត ដែលធ្វើការងារផ្នែកអាហារូបត្ថម្ភ
- ទទួលបានការគាំទ្រសម្រាប់ការរៀបចំគោលនយោបាយស្តីពីអាហារូបត្ថម្ភនៅកន្លែងធ្វើការ និងទទួលបានការអនុវត្តល្អ ដំបូន្មាន និងឧបករណ៍នៅថ្នាក់សកល និងថ្នាក់ជាតិ
- ទទួលបានដំបូន្មាន ការណែនាំ និងការបណ្តុះបណ្តាល តាមរយៈសិក្ខាសាលា និងព្រឹត្តិការណ៍នានា ដើម្បីបង្កើនការចូលរួមជាលក្ខណៈពាណិជ្ជកម្មរបស់ក្រុមហ៊ុននៅក្នុងវិស័យអាហារូបត្ថម្ភ
- ទទួលបានព័ត៌មានបច្ចុប្បន្នភាពស្តីពីឧស្សាហកម្មអាហារ ព្រមទាំងការផ្លាស់ប្តូរគោលនយោបាយពាក់ព័ន្ធ ដែលអាចមានឥទ្ធិពលលើការសម្រេចចិត្តនៅក្នុងការធ្វើអាជីវកម្ម
- រៀបចំករណីសិក្សា ដើម្បីជំរុញឱ្យមានការវិនិយោគបន្ថែមក្នុងវិស័យអាហារូបត្ថម្ភ
- រួមចំណែកដល់ការពិភាក្សានៅកម្រិតសកលស្តីពីការលើកកម្ពស់របបអាហារសុខភាព
- ទទួលបានបទពិសោធន៍ជាសកល/ចូលរួមនៅក្នុងចលនាជាតិ រួមនឹងព្រឹត្តិការណ៍ធំៗ
- ផ្តល់លទ្ធភាពឱ្យអាជីវកម្មនានាអាចបង្ហាញពីការរួមចំណែករបស់ខ្លួន ដល់ការលើកកម្ពស់នៅថ្នាក់ជាតិ និងថ្នាក់សកល

### ការទទួលខុសត្រូវរបស់សមាជិក

- គាំទ្រដល់បណ្តាញធុរកិច្ចនៃចលនា បង្កើនអាហារូបត្ថម្ភ និងចូលរួមឱ្យបានសកម្មនៅក្នុងការសម្រេចចក្ខុវិស័យ
- ជំរុញឱ្យអាជីវកម្មនានា ធ្វើសកម្មភាព ដើម្បីឆ្ពោះទៅលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ ដែលអាចមានផលជះដល់សុខភាពសាធារណៈនៅក្នុងប្រទេសរបស់ពួកគេ
- គោរពតាមគោលការណ៍ នៃចូលរួមសហការរបស់ចលនា បង្កើនអាហារូបត្ថម្ភ និងបណ្តាញធុរកិច្ចនៃចលនាបង្កើនអាហារូបត្ថម្ភ
- ចែករំលែកព័ត៌មានទូទៅ អំពីស្ថាប័ន និងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីគាំទ្រដល់អាហារូបត្ថម្ភ
- ផ្សព្វផ្សាយលក់ផលិតផលប្រើប្រាស់ (consumables) ដែលគោរពយ៉ាងភ្ជាប់ភ្ជួនទៅតាមក្របខ័ណ្ឌគតិយុត្តិជាតិដែលចូលជាធរមាន



សម្រាប់ភាសាអង់គ្លេស សូមមើលនៅផ្នែកម្ខាងទៀត

Flip over for English version